

រាយការណ៍ស្រាវជ្រាវស្តីពី

# “ផលប៉ះពាល់ពីការរាតត្បាតនៃជំងឺកូវីដ-១៩ មកលើកសិករ និង អ្នកផលិតស្បៀងអាហារខ្នាតតូចនៅកម្ពុជា”

បោះពុម្ពផ្សាយនៅខែធ្នូ ឆ្នាំ ២០២១

**មាតិកា**


**សេចក្តីថ្លែងអំណរគុណ** ០១

**របកគំហើញសង្ខេប** ០២

**សេចក្តីផ្តើម** ១១

អំពីរបាយការណ៍ ១៤

គោលបំណងការសិក្សាស្រាវជ្រាវ ១៤

វិធីសាស្ត្រ និងកម្រិតភាព ១៥

**របកគំហើញ**

ព័ត៌មានទូទៅរបស់កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូច ១៧

បទពិសោធពីការទទួលបានព័ត៌មានពីវិធានទប់ស្កាត់ការរីករាលដាលនៃ និងយន្តការគាំទ្រនានារបស់រដ្ឋាភិបាល ១៩

ផលប៉ះពាល់ពីការរាតត្បាតនៃជំងឺកូវីដ-១៩ មកលើសុខភាពកសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូច ២៧

ផលប៉ះពាល់លើជីវភាព និងការគាំទ្រនានារបស់រដ្ឋាភិបាលមកដល់កសិករខ្នាតតូច ៣០

បញ្ហាកង្វះស្បៀងអាហារ និងការគាំទ្រដល់កសិករនិងអ្នកផលិតស្បៀង អាហារខ្នាតតូច ៣៤

បញ្ហាអន្ទាក់ និងវដ្តនៃបំណុលរបស់កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូច ៤០

បញ្ហាទន្ទ្រានដីធ្លី និងធនធានធម្មជាតិ និងបញ្ហាជម្លោះដីធ្លី ៤៣

**សេចក្តីសន្និដ្ឋាន** ៤៧

សំណូមពរ តម្រូវការ និងអនុសាសន៍ ៥០

**ឯកសារយោង** ៥២

# សេចក្តីថ្លែងអំណរគុណ

អង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ បណ្តាញពហុវិស័យនៃអង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍ កម្មវិធីផ្តោតទៅលើលោកខាងត្បូង និងតំណាងអ្នកស្រែ កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចមួយចំនួនដែលបានចូលរួមក្នុងដំណើរការស្រាវជ្រាវពី **“ផលប៉ះពាល់នៃការរាតត្បាតពីជំងឺកូវីដ-១៩ មកលើកសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូច”** សូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅចំពោះ កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូច អ្នកស្រែ អ្នកនេសាទ តំណាងសហគមន៍ដីធ្លី តំណាងសហគមន៍ជនជាតិដើមភាគតិច ព្រមទាំងតំណាងសហគមន៍មូលដ្ឋានមួយចំនួនទៀត ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមផ្តល់កិច្ចសម្ភាសន៍ជាមួយ ក្រុមការងារស្រាវជ្រាវយើងខ្ញុំ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច តំណាងសហគមន៍មូលដ្ឋានព្រមទាំងនិស្សិតស្ម័គ្រចិត្តជាច្រើននាក់ដែលបានចូលរួមយ៉ាងសកម្ម ទាំងកម្លាំងកាយចិត្តនៅក្នុងដំណើរការសិក្សាស្រាវជ្រាវនេះទាំងមូល។

យើងខ្ញុំក៏សូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណដល់ក្រុមការងារបច្ចេកទេស នៃសម្ព័ន្ធបងប្អូនស្រីសមាគមអង្គការ ជាសមាជិកនៃសម្ព័ន្ធបងប្អូនស្រីដែលបានចូលរួមចំណែកយ៉ាងសកម្មទាំងការគាំទ្រផ្នែកស្មារតី បច្ចេកទេស និងផ្តល់យោបល់មកលើដំណើរការចងក្រង និងផលិតឯកសិក្សាសារស្រាវជ្រាវមួយនេះឡើង។

# របកគំហើញសង្ខេប

> *“ពេលខ្ញុំនៅមណ្ឌលចត្តាឡីស័ក ខ្ញុំបានលឺគេនិយាយថា មានការឧបត្ថម្ភសាច់ប្រាក់ចំនួន ២ម៉ឺនរៀលសម្រាប់ម្នាក់ ក្នុងមួយថ្ងៃ។ ប៉ុន្តែ ខ្ញុំមិនបានទទួលប្រាក់នោះទេសូម្បីមួយរយរៀល។ ហើយគេ (អ្នកគ្រប់គ្រងមណ្ឌលចត្តាឡីស័ក) ចង់ទុកខ្ញុំនៅក្នុងមណ្ឌលនោះ ១៦ថ្ងៃ ដែលវាលើសទៅនឹងការកំណត់នៃការធ្វើចត្តាឡីស័ក បើតាមព័ត៌មានដែលខ្ញុំបានស្តាប់។ ខ្ញុំបានតវ៉ាឱ្យដាក់ខ្ញុំត្រឹមតែ ១៤ថ្ងៃ។ មណ្ឌលផ្តល់អាហារ ៣ពេល ប៉ុន្តែមានភាពយឺតយ៉ាវ ឧទាហរណ៍ អាហារពេលព្រឹក គេផ្តល់ឱ្យនៅម៉ោង ១០ព្រឹក ហើយអាហារថ្ងៃត្រង់គេផ្តល់ឱ្យនៅម៉ោងប្រមាណ ២ ឬ ៣រសៀល។*
>
> *សម្តីកសិករម្នាក់ដែលមានបទពិសោធក្នុងមណ្ឌលចត្តាឡីស័កមួយកន្លែងក្នុងខេត្តប៉ៃលិន។”*

> *“កូនស្រីខ្ញុំ គ្រប់ខែឆ្លងទន្លេ (សម្រាលកូន) ខ្ញុំបាននាំនាងទៅមណ្ឌលសុខភាពមួយ។ មណ្ឌលសុខភាពទុកនាងចោលមួយរសៀល ដោយប្រាប់ឱ្យខ្ញុំនិងគ្រួសារឱ្យនៅរង់ចាំ។ រហូតដល់យប់បន្តិច ទើបខាងមណ្ឌលសុខភាពប្រាប់ខ្ញុំថា ស្ថានភាពកូនស្រីខ្ញុំធ្ងន់ធ្ងរត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែក។ ទម្រាំរៀបចំឯកសារផ្ទេររួច កូនខ្ញុំឈឺពោះរង់ចាំរហូតដល់ងងឹត។ ពេលទៅដល់មន្ទីរពេទ្យបង្អែក បុគ្គលិកពេទ្យទីនោះ តម្រូវឱ្យកូនស្រីខ្ញុំនិងពួកយើងធ្វើតេស្តរកកូវីដ-១៩ ម្តងទៀត ដោយអះអាងថា តេស្តនៅមណ្ឌលសុខភាពមិនអាចយកជាការបានទេ។ ធ្វើតេស្តរួច ខាងមន្ទីរពេទ្យបង្អែកតម្រូវឱ្យរង់ចាំលទ្ធផលតេស្តសិន ហើយទុកកូនខ្ញុំចោលរហូតដល់ពាក់កណ្តាលយប់ បន្ទាប់មកគេប្រាប់ថា អត់មានពេទ្យទេ គេតម្រូវឱ្យបញ្ជូនកូនខ្ញុំទៅមន្ទីរពេទ្យបង្អែកខេត្តមួយទៀត។ ខ្ញុំបានរករឿង មិនព្រមយកកូនចេញពីពេទ្យ ព្រោះវាយប់ខ្លាំងណាស់ (ពាក់កណ្តាលអាធ្រាត្រ) ខ្លាចប៉ះពាល់ជីវិតកូនស្រីខ្ញុំ ពួកយើងរង់ចាំរហូតដល់ព្រឹកទើបមានពេទ្យ។ កូនខ្ញុំសំណាងល្អណាស់ដែលអាយុវែង។*
>
> *សម្តីស្ត្រីកសិករម្នាក់ដែលរស់នៅក្នុងខេត្តព្រះវិហារ រៀបរាប់ពីបទពិសោធន៍របស់កូនស្រីគាត់”*

## បទពិសោធន៍ពីការទទួលបានព័ត៌មាន ពីវិធានទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងយន្តការនានារបស់រដ្ឋាភិបាល

កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ១០៤នាក់ ចូលរួមផ្តល់បទសម្ភាសន៍។ ក្នុងចំណោមនោះ កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចជាស្ត្រីមានចំនួន ៤៥នាក់ ឬស្មើនឹង ៤៣.៣ភាគរយ បើធៀបទៅនឹងកសិករបុរសដែលមានចំនួន ៥៩នាក់ ឬស្មើនឹង ៥៦.៧ភាគរយ។

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៩៦នាក់ (៩២.៣ភាគរយ) ធ្លាប់ទទួលបានព័ត៌មានពីវិធានបង្ការជំងឺកូវីដ-១៩ ឬវិធានបីកុំ បីការពារ ដែលមានដូចជា ការលាងសម្អាតដៃជាប្រចាំ ពាក់ម៉ាស់ រក្សាគម្លាត និងមិនទៅកន្លែងចង្អៀតបិទជិតពីសំណាក់អាជ្ញាធរមូលដ្ឋាន។

កសិករចំនួន ៧៨នាក់ ឬស្មើនឹង ៧៥ភាគរយ ដឹងពីកម្មវិធីផ្តល់សាច់ប្រាក់ដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះក្នុងវិបត្តិជំងឺកូវីដ-១៩ តាមរយៈប័ណ្ណក្រីក្រពីសំណាក់រាជរដ្ឋាភិបាល នៅពេលដែលកសិករចំនួន ២៦នាក់ ស្មើឬនឹង ២៥ភាគរយ មិនបានដឹងអំពីកម្មវិធីនេះ។ ដោយឡែកកសិករចំនួន ៤៤.២ភាគរយ មិនបានដឹងអំពីការគាំទ្រអាហារសម្រាប់ប្រជាជនក្នុងអំឡុងពេលធ្វើចត្តាឡីស័កទាំងនៅមណ្ឌលចត្តាឡីស័ក ឬនៅផ្ទះ នៅពេលដែលកសិករចំនួន ៥៥.៨ភាគរយផ្សេងទៀត បានដឹងអំពីការគាំទ្រនេះ។

កសិករចំនួន ៧៨.៨ភាគរយ មិនបានដឹងពីកម្មវិធីឥណទានគាំទ្រដល់សហគ្រិនកសិកម្មខ្នាតតូច និងមធ្យមជាមួយទឹកប្រាក់ ៥០លានដុល្លារ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដោយអាត្រាការប្រាក់ទាប បើធៀបទៅនឹងកសិករចំនួនត្រឹមតែ ១៨.៣ភាគរយ បានដឹងពីការគាំទ្រនេះ។ កសិករច្រើនលើសលុប (៨៣.៧ភាគរយ) មិនបានដឹងឬទទួលបានព័ត៌មានអំពីការជួយប្រមូលទិញផលិតផលកសិកម្មរបស់កសិករខ្នាតតូចនិងមធ្យមក្នុងតំលៃសមរម្យ។

កសិករ ៦៦.៣ភាគរយ មិនបានដឹងអំពីអន្តាគមន៍បន្ថែមរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដើម្បីគាំពារដល់អតិថិជនក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ ដែលត្រូវបានចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០២១ នៅក្នុងសេចក្តីថ្លែងការណ៍រួមរបស់សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុនៅកម្ពុជាកន្លង។

កសិករជាង ៤០ភាគរយ មិនបានទទួលព័ត៌មានពីច្បាប់ស្តីពី វិធានទប់ស្កាត់ជំងឺកូវីដ-១៩។ ដោយឡែក ៦០.៦ភាគរយ បានទទួលព័ត៌មានអំពីអនុក្រិត្យស្តីពីកាតព្វកិច្ចក្នុងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩។ កសិករចំនួន ៧៦.៩ភាគរយ បានដឹងពីសេចក្តីសម្រេចស្តីពី ការពិន័យអន្តរការណ៍ចំពោះបុគ្គលដែលមិនគោរពដោយចេតនា វិធានរដ្ឋបាលក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។ កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច ចំនួនច្រើន ឬ ៨៥.៦ភាគរយ បានទទួលព័ត៌មានអំពីសេចក្តីសម្រេចស្តីពី ការហាមឃាត់ការធ្វើដំណើរ និងការបិទរមណីដ្ឋានទេសចរណ៍ទូទាំងប្រទេសជាបណ្តោះអាសន្ន។

កសិករមួយចំនួនធំ បង្ហាញក្ដីបារម្ភ និងសម្ដែងនូវការមិនពេញចិត្តមួយចំនួនចំពោះការតាក់តែងនិងអនុម័តច្បាប់ស្ដីពី "វិធានទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត" ដោយលើកឡើងថា ច្បាប់នេះមិនគួរត្រូវបានអនុម័តក្នុងកាលៈទេសៈនេះទេ។ ពួកគាត់ បានលើកឡើងថា ដំណើរការតាក់តែង និងអនុម័តច្បាប់នេះត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័ស ហើយមិនបានបញ្ចូលកិច្ចពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាសាធារណៈ ព្រមជាមួយការកំណត់ទោសទណ្ឌ និងការផាកពិន័យដែលមានចែងក្នុងច្បាប់នេះ អាចធ្វើឱ្យពលរដ្ឋមានបន្ទុកបន្ថែមពិសេសជុំវិញពិន័យដែលមានចែង។

## ផលប៉ះពាល់ពីការរាតត្បាតនៃជំងឺកូវីដ-១៩ មកលើសុខភាពកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៧៧.៩ភាគរយ មិនបានទទួលការគាំទ្រនូវសម្ភារការពារខ្លួន ដូចជា ម៉ាស់ អាល់កុល ឬសាប៊ូលាងដៃពីរដ្ឋាភិបាល ឬអាជ្ញាធរមូលដ្ឋាននោះទេ បើធៀបទៅនឹងកសិករចំនួន ២០.២ភាគរយ ដែលបានទទួលការគាំទ្រសម្ភារការពារខ្លួន។ ការចំណាយទៅលើសម្ភារការពារខ្លួនក្នុងបរិបទដ៏ពិបាកនេះ ជាបន្ទុកបន្ថែមដែលរបស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច។ អាចផ្ដត់ផ្ដង់ទៅលើការចំណាយម្ហូបអាហារប្រចាំថ្ងៃ។

កសិករចំនួន ៨៨.៥ភាគរយ មិនធ្លាប់មានបទពិសោធដោយផ្ទាល់ ឬមានសមាជិកគ្រួសារដែលបានធ្វើចត្តាឡីស័កក្នុងអំឡុងពេលនៃការស្រាវជ្រាវ បើធៀបទៅនឹងកសិករចំនួន ១១.៥ភាគរយ ដែលធ្លាប់បានឆ្លងកាត់បទពិសោធន៍ធ្វើចត្តាឡីស័ក ហើយក្នុងចំណោមកសិករឬសមាជិកគ្រួសារពួកគេដែលមានបទពិសោធន៍ធ្វើចត្តាឡីស័ក កសិករមួយចំនួនតូច បានទទួលការគាំទ្រក្នុងអំឡុងពេលនោះ។

ថ្វីបើ វិធានសុខាភិបាលរបស់រដ្ឋាភិបាលចំពោះការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ទទួលបានការកោតសសើរពីសំណាក់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចភាគច្រើនក្ដី ក្នុងចំណោមនោះ ពួកគេមួយចំនួនក៏បានបង្ហាញនូវភាពមិនពេញចិត្តចំពោះការទៅទទួល និងប្រើប្រាស់សេវាសុខភាពនាអំឡុងពេលពីការរាតត្បាតនៃជំងឺកូវីដ-១៩ ថាមិនមានការយកចិត្តទុកដាក់ មានការរើសអើង និងទុកឱ្យអ្នកជំងឺស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដល់អាយុជីវិត ដោយសារការបារម្ភ និងមានការភ័យខ្លាចខ្លាំងចំពោះការឆ្លងជំងឺកូវីដ-១៩។ កសិករមួយចំនួនតូច មានបទពិសោធន៍មិនទទួលបានអត្ថប្រយោជន៍ ឬការទូទាត់នៅពេលទៅប្រើប្រាស់សេវាថែទាំ និងព្យាបាលពីការប្រើប្រាស់ប័ណ្ណបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នាអំឡុងពេលនៃការរាតត្បាតពីជំងឺកូវីដ-១៩។ ពួកគាត់ត្រូវបានតម្រូវឱ្យបង់ប្រាក់សម្រាប់ការសម្រាកព្យាបាលនៅពេលទៅប្រើប្រាស់សេវាទាំងនៅមន្ទីរពេទ្យរដ្ឋ និងមន្ទីរពេទ្យឬគ្លីនីកឯកជន។

បញ្ហាមួយចំនួនទៀតសម្រាប់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចជុំវិញការប្រើប្រាស់សេវាសុខភាពពេលគឺការចំណាយច្រើនជាងមុនទៅលើសេវានេះ ជាក់ស្ដែងក្នុងករណីសមាជិកគ្រួសារមានជំងឺតម្រូវឱ្យសម្រាកព្យាបាល ឬពិគ្រោះយោបល់ ខាងមន្ទីរពេទ្យតម្រូវឱ្យពួកគេធ្វើតេស្តរកកូវីដ-១៩ ជាមុន

ហើយតម្លៃនៃការធ្វើតេស្តមានភាពផ្សេងៗគ្នាទៅលើតាមតំបន់នីមួយៗ ហើយដែលតម្លៃអាចចាប់ពី ៥ម៉ឺនរៀល (១២.៥ដុល្លារ) ទៅ ១២ម៉ឺនរៀល (៣០ដុល្លារ) សម្រាប់ការធ្វើតេស្តម្តង។ ការចំណាយទៅលើការធ្វើតេស្តនេះ ជាបន្ទុកមួយទៀតសម្រាប់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច។

## ផលប៉ះពាល់លើជីវភាព និងការគាំទ្រនានារបស់រដ្ឋាភិបាលដល់កសិករខ្នាតតូច

កសិករចំនួន ៩២.២ភាគរយ មានចំណូលទាបជាងមុន ហើយបញ្ហាការធ្លាក់ចុះនៃចំណូលនេះ គឺកើតឡើងចាប់តាំងពីមានការរាតត្បាតនៃជំងឺកូវីដ-១៩។

រីឯផលិតផលកសិកម្មរួមមាន ស្រូវ បន្លែ ការចិញ្ចឹមសត្វ រួមទាំងផលិតផលមួយចំនួនដែលផលិតបាននៅក្នុងសហគមន៍ គឺបន្តជួបប្រទះនៅការធ្លាក់ចុះតម្លៃ ឬលក់មិនចេញ បើធៀបទៅនឹងតម្លៃទំនិញនៅលើទីផ្សារបន្តឡើងខ្ពស់។

បន្លែ (ដូចជាម្ទេស ត្រប់ស្រួយ ឆៃថាវ និងត្រប់វែង) និងផ្លែឈើមានតម្លៃធ្លាក់ចុះខ្លាំងផ្ទុយពីបន្លែនៅលើទីផ្សារដែលនាំចូលថ្លៃជាងមុន ជាហេតុកសិករមួយចំនួនសម្រេចចិត្តភ្ជួរបន្លែរបស់ពួកគាត់ចោល។ ដោយឡែក តម្លៃធាតុចូលកសិកម្មបន្តកើនឡើង ជាក់ស្តែង ថ្នាំពុលនិងជីគីមីកសិកម្មបន្តឡើងថ្លៃខ្ពស់ ជាងមុន ជាអាទិ៍ជីបំប៉នស្រូវ អ៊ុយរ៉េ ពីមុនមានតម្លៃ ៨ម៉ឺនក្នុង (២០ដុល្លារ) ក្នុង ១បាវ ឬស្មើនឹង ៥០គីឡូក្រាមនៅក្នុងឆ្នាំ ២០២០ ហើយបច្ចុប្បន្នតម្លៃជី ១បាវ ឬស្មើនឹង ៥០គីឡូក្រាម បានឡើងដល់ ១២ម៉ឺន (៣០ដុល្លារ) ទៅដល់ ១៩ម៉ឺនរៀល (៤៧.៥ដុល្លារ) ក្នុង ១បាវ ឬស្មើនឹង ៥០គីឡូក្រាម ក្នុងឆ្នាំ ២០២១។

កសិករចំនួន ១០០នាក់ ឬស្មើនឹង ៩២.២ភាគរយ មិនធ្លាប់ទទួលបានការគាំទ្រពីកម្មវិធីឥណទានគាំទ្រដល់សហគ្រាសកសិកម្មខ្នាតតូច និងមធ្យមដែលមានទឹកប្រាក់ជាមួយទឹកប្រាក់ ៥០លានដុល្លារតាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ជាមួយអាត្រាការប្រាក់ទាបនោះទេ។

## បញ្ហាកង្វះស្បៀងអាហារ និងការគាំទ្រដល់កសិករនិងអ្នកផលិតស្បៀង អាហារខ្នាតតូច

កសិករ ៦២នាក់ ឬស្មើនឹង ៥៩.៦ភាគរយ មិនមានអាហារសម្រាប់ទទួលទានគ្រប់គ្រាន់ បើធៀបទៅនឹង កសិករ ៤១នាក់ ឬស្មើនឹង ៣៩.៤ភាគរយដែលមានអាហារទទួលទានគ្រប់គ្រាន់។ កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៤០.៤ភាគរយ ចំណាយទៅលើអាហារជាមធ្យមចន្លោះពី ១១,០០០រៀល-២០,០០០រៀល (២.៧ដុល្លារ-៥ដុល្លារ) ក្នុងមួយថ្ងៃសម្រាប់មួយគ្រួសារ។

កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៧៥ភាគរយ មិនទទួលបានការគាំទ្រពីកម្មវិធីផ្តល់សាច់ប្រាក់ជូនគ្រួសារក្រីក្រ និងជនងាយរងគ្រោះក្នុងវិបត្តិនៃជំងឺកូវីដ-១៩ បើធៀបទៅនឹងកសិករមានត្រឹមតែចំនួន ២៤ភាគរយប៉ុណ្ណោះដែលទទួលបានការគាំទ្រពីកម្មវិធីនេះ។



*រូបភាពបង្ហាញពីកសិករព្រោះស្រូវធ្វើសំណាប នៅខេត្តបាត់ដំបង*

ក្នុងតំបន់នៃខេត្តមួយចំនួន ប្រឡាយរួម ឬទឹកស្ទឹងរួមត្រូវបានធ្វើអាជីវកម្មដោយក្រុមហ៊ុន ឬបុគ្គលមានធនធានឯកជនក្នុងស្រុក ហើយពួកគេមានសិទ្ធិទៅលើការកំណត់តម្លៃទឹកដែលកសិករនិងអ្នកផលិតស្បៀងអាហារប្រើប្រាស់។ ជាក់ស្តែង កសិករខ្នាតតូចក្នុងខេត្តចំនួនពីរ លើកឡើងពីបញ្ហាការចំណាយទៅលើទឹកសម្រាប់ក្នុងការបង្កបង្កើនផលដែលមានតម្លៃចន្លោះពី ២៥ម៉ឺនរៀល (៦២.៥ដុល្លារ) ទៅដល់ ៣៥ម៉ឺនរៀល (៨៧.៥ដុល្លារ) ក្នុងមួយហិចតាទៅកាន់អ្នកផ្គត់ផ្គង់ទឹកឯកជនដែលបានទទួលការអនុញ្ញាតលក់ទឹកប្រឡាយឱ្យកសិករ។ ចំពោះតម្លៃទឹកនេះទៀតសោតមិនបានបញ្ចូលការចំណាយរបស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចទៅលើការចំណាយម៉ាស៊ូតដើម្បីបូមទឹកដាក់ស្រែរបស់ពួកគាត់។

កសិករមួយចំនួនបានជ្រើសរើសបណ្តាក់ស្បៀងអាហារ(ជំពាក់ប្រាក់ទៅលើថ្លៃអាហារ) ម្តងម្កាលពីអ្នកភូមិផ្សេងទៀត ឬដោយការសន្សំសំចៃ និងកាត់បន្ថយការចំណាយទៅលើរបប និងបរិមានអាហារ (ដូចជាដោយការទទួលទានស៊ុត(ពងទា ពងមាន់) ទឹកត្រី ឬបន្លែដែលពួកគាត់ដាំបាន ឬរកបាននៅជុំវិញផ្ទះ ឬស្រែជាដើម) ឬការកាត់បន្ថយអាហារពីមួយថ្ងៃបីពេលមកត្រឹមពីរពេលជំនួសវិញ។

## បញ្ហាចង្អៀតនៃបំណុល និងអន្តរាគមន៍របស់រដ្ឋាភិបាល

កសិករចំនួន ៥១.១ភាគរយ ធ្លាប់មានការលំបាកក្នុងការសងបំណុលត្រឡប់ទៅកាន់ស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬធនាគារពាណិជ្ជក្នុងអំឡុងពេលនៃវិបត្តិពីការរាតត្បាតនៃជំងឺកូវីដ-១៩ បើយោងទៅតាមរបាយការណ៍ឆ្នាំ ២០២០។

ក្រៅពីការសុំចរចា និងខ្ចីប្រាក់ខាងលើ កសិករចំនួន ៣៥.៧ភាគរយ បានព្យាយាមកាត់បន្ថយចំណាយទៅលើអាហារ និង៤១.១ភាគរយ ព្យាយាមកាត់បន្ថយចំណាយនានានៅក្នុងផ្ទះ ដើម្បីសន្សំប្រាក់ទៅសងគេវិញ។ ម្យ៉ាងដោយការសិក្សាពីចម្ងាយរបស់កូនៗ ត្រូវការចំណាយច្រើនទៅលើកាតទូរស័ព្ទ និងសម្ភារអេឡិចត្រូនិចនានា ពួកគាត់ចំនួន ៨.៩ភាគរយ បានស្នើសុំឱ្យកូនៗឈប់រៀននៅអំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩ នេះ។

អ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៨៧.៥ភាគរយ មិនទទួលបានការសម្រួលការសងបំណុលត្រឡប់ និងបន្ធូបន្ថយអាត្រាការប្រាក់ជាមួយធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ហើយកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចមានចំនួនត្រឹមតែ ៥.៨ភាគរយ ដែលបានទទួលការសម្របសម្រួលបំណុលពីស្ថាប័នទាំងនេះ។



*រូបភាពបង្ហាញពីឈ្មួញប្រមូលទិញស្រូវពីកសិករ នៅក្នុងខេត្តបាត់ដំបង*

## បញ្ហាការទន្ទ្រានដីធ្លី ការរំលោភបំពានមកលើកសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចនាអំឡុងការរាតត្បាតពីជំងឺកូវីដ-១៩

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៤៧.១ភាគរយ រាយការណ៍ថាមានករណីរំលោភបំពាននៅអំឡុងពេលពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ហើយសកម្មភាពខុសច្បាប់មួយចំនួននៅតែបន្តដូចជា ការកាប់ដីបំផ្លាញព្រៃឈើ ព្រៃលិចទឹក និងធនធានធម្មជាតិ ដើម្បីយកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនពីសំណាក់ជនខិលខូច ហើយបញ្ហាការរំលោភបំពានដីធ្លី ការវាយកម្ទេចភ្នំ ការនេសាទខុសច្បាប់ ក៏ត្រូវបានរាយការណ៍ផងដែរ។

សកម្មភាពនៃការបៀតបៀន ការរើសអើង ឬអំពើហិង្សាមានទម្រង់ខុសៗគ្នា។ កសិករមួយចំនួនថាការរើសអើងកើតឡើងនៅពេលដែលសមាជិកគ្រួសាររបស់ពួកគាត់មានជំងឺគ្រុនផ្តាសាយ ហើយជាពិសេសអ្នកដែលមានសមាជិកនៅទីក្រុងភ្នំពេញ ត្រូវបានអាជ្ញាធរបញ្ជូនយកទៅធ្វើចត្តាឡីស័ក។

ការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ នៅអំឡុងពេលនៃការរាតត្បាតពីជំងឺកូវីដ-១៩ បន្តកើតមាន និងមានការកើនឡើង ដោយសារ សមាជិកគ្រួសារគ្មានការងារមិនមាន ប្រាក់ចំណូលរួមជាមួយភាពស្មុកស្មាញនិងតានតឹងមួយចំនួនទៀត។

ក្រៅពីបម្រាម និងការរឹតត្បិតការជួបជុំនានារបស់សហគមន៍ដើម្បីទប់ស្កាត់នូវការរីករាលដាលនៃជំងឺកូវីដ-១៩ កសិករមួយចំនួន ពិសេសដែលស្ថិតនៅក្នុងបញ្ហាទំនាស់ដីធ្លី នៅបន្តទទួលរងការចោទប្រកាន់ពេលដែលពួកគេព្យាយាមប្រមូលផ្តុំទាមទារសិទ្ធិដីធ្លី សំណង និងយុត្តិធម៌ក្រោមការចោទប្រកាន់ថាជាក្រុមអ្នកប្រឆាំង។

## សេចក្តីសន្និដ្ឋាន

ផលប៉ះពាល់ពីវិបត្តិនានាដែលស្តែងចេញពីការរាតត្បាតនៃជំងឺកូវីដ-១៩ មកលើកសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចបន្តមានសភាពធ្ងន់ធ្ងរ។ ផលប៉ះពាល់ទាំងនោះរួមមាន ទាំងបញ្ហាកង្វះស្បៀងអាហារ ការកាត់បន្ថយគុណភាព ឬបរិមាណនៃអាហាររបស់កសិករ។ បញ្ហាការធ្លាក់ចូលទៅក្នុងវដ្តនៃបំណុល និងភាពក្រីក្រក៏ជាបញ្ហាប្រឈម និងបន្តផ្តល់ផលប៉ះពាល់ទាំងផ្នែកសេដ្ឋកិច្ចគ្រួសារ មកលើស្មារតី ព្រមទាំងផ្លូវចិត្តរបស់ពួកគាត់ផងដែរ។

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចជាច្រើន ក៏នៅបន្តជួបប្រទះនិងទទួលរងគ្រោះចំពោះការចំណាយច្រើនទៅលើធាតុចូល និងសម្ភារសម្រាប់បង្ករបង្កើនផល ដែលវាផ្ទុយពីផលដែលពួកគាត់បានទទួលត្រឡប់នាពេលប្រមូលកសិផល។ តម្លៃកសិផលបន្តត្រូវបានគ្រប់គ្រងកំណត់ដោយអ្នកទិញ ឬឈ្មួញកណ្តាល ឬរោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុនកសិ-ឧស្សាហកម្មដដែល។ កសិករភាគច្រើនមិនមានភាពជាម្ចាស់ ឬអំណាចទៅលើការកំណត់តម្លៃកសិផលដែលខ្លួនបានផលិតនោះទេ។ ការហូរចូលនៃកសិផលពីក្រៅប្រទេស ពិសេសពីប្រទេសជិតខាង បន្តផ្តល់ផលប៉ះពាល់ដល់កសិផលដែលផលិតបានដោយកសិករខ្នាតតូចក្នុងស្រុក ហើយកសិផលទាំងនោះទៀតសោត បន្តមានតម្លៃថ្លៃជាងតម្លៃកសិផលរបស់កសិករក្នុងស្រុក។ ស្របពេលដែលកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចក្នុងស្រុកមិនទទួលបានការគាំទ្របច្ចេកទេស ការឧបត្ថម្ភធន សម្របសម្រួលឬធានាទីផ្សារសម្រាប់កសិករ។

បន្ថែមទៅលើកម្រិតភាពនៃការដោះស្រាយបញ្ហា ឬការផ្តល់ការគាំទ្ររបស់រដ្ឋាភិបាល ចំពោះកសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចដែលរងគ្រោះ ការដាក់ចេញឱ្យអនុវត្តវិធាន ការតាក់តែងនិងអនុម័តច្បាប់ សេចក្តីសម្រេច និងការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមួយចំនួនធ្វើឡើងយ៉ាងឆាប់រហ័ស ដោយមិនបានបញ្ចូលកច្ចពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាសាធារណៈ ឬក៏សិក្សាអំពីផលប៉ះពាល់របស់វាជាលក្ខណៈអវិជ្ជមានជាមុន។

វិបត្តិដែលបង្កឡើងពីបម្រែបម្រួលអាកាសធាតុ បានជម្រុញឱ្យកសិករខ្នាតតូច ខាតបង់ថវិកា ឬបាត់បង់ជីវភាពដោយសារការបំផ្លិចបំផ្លាញស្ទើរទាំងស្រុង នៃកសិផលរបស់ពួកគាត់ដោយសារគ្រោះទឹកជំនន់ និងរាំងស្ងួត នាអំឡុងពេលពីរឆ្នាំជាប់ៗគ្នា។ ផលប៉ះពាល់នេះ បណ្តាលឱ្យកសិករមួយចំនួនពិចារណាក្នុងការផ្អាកធ្វើកសិកម្មមួយរយៈដោយសារការចំណាយច្រើន ហើយមិនទទួលបានផលត្រឡប់មកវិញ។

តម្រូវការរបស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចមិនទាន់ត្រូវបានដោះស្រាយ ឬឆ្លើយតបពីសំណាក់រដ្ឋាភិបាល ក្រសួង និងស្ថប័នពាក់ព័ន្ធមួយចំនួនជាលក្ខណៈបន្ទាន់ និងជាលក្ខណៈប្រព័ន្ធនៅឡើយនោះទេ។ ផងដែរ ដោយសារផលប៉ះពាល់ពីវិបត្តិនានាពីការរាតត្បាតនៃជំងឺកូវីដ-១៩ មកលើកសិករមានភាពធ្ងន់ធ្ងរ ការស្តារឡើងវិញនូវជីវភាពរបស់ពួកគាត់ មានសារៈសំខាន់ដែលត្រូវការការគាំទ្រ

ជាចាំបាច់ និងជាការបន្ទាន់។ ការឆ្លើយតប និងការស្តារឡើងវិញទៅលើជីវភាពរបស់កសិករ គឺគួរត្រូវដោះស្រាយទាំងជាលក្ខណៈប្រព័ន្ធ ដោយសារបញ្ហាទាំងនោះបន្តកើតមានឡើងហើយវាមានភាពរ៉ាំរ៉ៃ ជាអាទិ៍បញ្ហាកង្វះការគាំទ្រការឧបត្ថម្ភធនដល់កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចក្នុងដំណើរការផលិត បញ្ហាវដ្តនៃបំណុល និងបញ្ហាអត្រាការប្រាក់ខ្ពស់ពីប្រាក់កម្ចីពីធនាគារពាណិជ្ជ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ ព្រមទាំងការមិនលើកលែងបំណុលបើទោះបីជាកសិករស្ថិតក្នុងស្ថានភាពលំបាក បញ្ហាការគ្រប់គ្រងការកំណត់តម្លៃទីផ្សារពីឈ្មួញ ឬអ្នកទិញ និងបញ្ហាកម្រិតភាពនៃប្រព័ន្ធកិច្ចគាំពារសង្គមចំពោះកសិករ ជាដើម។ល។

# សេចក្តីផ្តើម

ប្រទេសកម្ពុជា បន្តទទួលរងនូវផលប៉ះពាល់ពីវិបត្តិនានាទៅលើទាំងផ្នែកសេដ្ឋកិច្ច និងសង្គមដែលបណ្តាលពីការរាតត្បាតនៃជំងឺកូវីដ-១៩ និងបម្រែបម្រួលអាកាសធាតុនាអំឡុងពេលពីរឆ្នាំចុងក្រោយនេះ។ ការណ៍នេះ បាន បណ្តាលឱ្យកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចជាច្រើន ទទួលរងនូវផលប៉ះពាល់អវិជ្ជមានពីវិបត្តិទាំងនោះយ៉ាងធ្ងន់ធ្ងរ។

គិតត្រឹមថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០២១ ករណីជំងឺកូវីដ-១៩ ចំនួន ១១៩,៧៨៦ ត្រូវបានរាយការណ៍។ ក្នុងនោះ ចំនួនអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ មានរហូតដល់ទៅ ២,៨៩១នាក់ ហើយករណីជាសះស្បើយមានចំនួន ១១៦,១៧០នាក់។ ដើម្បីគ្រប់គ្រង និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេស រាជរដ្ឋាភិបាលបានដាក់ចេញវិធានរដ្ឋបាល វិធានសុខាភិបាលនិងវិធានផ្សេងៗ ព្រមទាំងកម្មវិធីឆ្លើយតបមួយចំនួន។ ជាអាទិ៍សេចក្តីសម្រេចបិទខ្ទប់រាជធានីភ្នំពេញ និងទីក្រុងតាខ្មៅក្នុងអំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីជាតិ ដោយគិតចាប់ពីម៉ោងសូន្យឈានចូលថ្ងៃទី ១៥ ខែមេសា ដល់ថ្ងៃទី ២៨ ខែមេសាឆ្នាំ ២០២១ និងដោយសម្រេចបន្តបិទខ្ទប់ដល់ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០២១។ ការបិទខ្ទប់តំបន់ភូមិសាស្ត្រនៅរាជធានី-ខេត្តទូទាំងប្រទេស ការដាក់ចេញឱ្យអនុវត្តនូវបម្រាមគោចរក្នុងរាជធានី និងបណ្តាខេត្តនានាដោយធ្វើការរឹតត្បិតការធ្វើដំណើរឆ្លងខេត្ត អនុវត្តន៍វិធានចត្តាឡីស័កសម្រាប់អ្នកធ្វើដំណើរឆ្លងខេត្ត និងចូលមកកាន់កម្ពុជា ការបន្តបិទផ្អាកជាបណ្តោះអាសន្នវិស័យធំៗជាច្រើន ដោយរួមទាំងវិស័យទេសចរណ៍ (ភោជនីយដ្ឋានរមនីយដ្ឋានទេសចរណ៍នានា) បន្តរឹតត្បិតការធ្វើដំណើរច្រកអន្តរជាតិ (ច្រកព្រំដែនផ្លូវគោកនានា) និងមិនអនុញ្ញាត្តិចំពោះការជួបជុំទាំងកម្មវិធីជួបជុំបែបសង្គម ឬពិធីបុណ្យសាសនាជាដើម។ល។

បន្ថែម ទៅលើវិធានដែលបានដាក់ចេញខាងលើ ច្បាប់មួយចំនួនទៀតត្រូវបានតាក់តែង និងអនុម័ត ឬធ្វើពិសោធនកម្ម ដោយបានប្រកាសឱ្យអនុវត្តជាការបន្ទាន់។ តួយ៉ាង ច្បាប់ស្តីពី “វិធានទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត” ត្រូវបានតាក់តែងនិងអនុម័តក្នុងសប្តាហ៍ទីពីរនៃខែមីនា ឆ្នាំ ២០២១។

ទន្ទឹមនឹងនេះ រដ្ឋាភិបាលក៏បានខិតខំខ្នែងបញ្ចប់ការចរចាទៅលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ទាំងលក្ខណៈទ្វេភាគី និងពហុភាគីជាមួយប្រទេសមួយចំនួនក្នុងគោលបំណងទាក់ទាញវិនិយោគដោយផ្ទាល់ពីបរទេសមកកាន់កម្ពុជា ព្រមទាំងការពង្រីកវិសាលភាពនាំផលិតផលកម្ពុជាចូល



រូបភាពបង្ហាញពីអាគារ នៅក្នុងទីក្រុងព្រះសីហនុ

ទៅកាន់ទីផ្សារក្នុងតំបន់ និងពិភពលោកដើម្បីស្តារឡើងវិញនូវកំណើនសេដ្ឋកិច្ច និងឆ្ពោះទៅដល់គោលដៅអភិវឌ្ឍកំណើនសេដ្ឋកិច្ច ក្រោយការគ្រប់គ្រងស្ថានភាពការរាតត្បាតពីជំងឺកូវីដ-១៩។ ដូចនេះហើយ យ៉ាងហោចណាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីចំនួនពីរ ត្រូវបានចុះហត្ថាលេខាជាផ្លូវការស្ថាពរក្នុងឆ្នាំ ២០២១។ ក្នុងនោះមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីរវាងប្រទេសកម្ពុជាជាមួយប្រទេសចិន និងកិច្ចព្រមព្រៀងទ្វេភាគីរវាងប្រទេសកម្ពុជាជាមួយប្រទេសកូរ៉េខាងត្បូង។ បន្ថែមទៅលើការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីទាំងពីរនេះ កម្ពុជាក៏បានចូលរួមបញ្ចប់ការចរចារទៅលើកិច្ចព្រមព្រៀងភាពជាដៃគូរពាណិជ្ជកម្មទូលំទូលាយថ្នាក់តំបន់ ឬហៅកាត់ជាភាសាអង់គ្លេសថា (RCEP)ដែលមានប្រទេសហត្ថលេខីចំនួន ១៥ ចូលរួម។

ទន្ទឹមនឹងនេះ ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវបានអនុម័តនិងប្រកាសដាក់ឱ្យប្រើប្រាស់ជាការប្រញាប់នាពេលថ្មីៗនេះ។ យ៉ាងណាមិញ អត្ថបទឬខ្លឹមសារទាំងស្រុងនៃកិច្ចព្រមព្រៀងទាំងនេះ មិនទាន់ត្រូវបានដាក់ផ្សព្វផ្សាយជាសាធារណៈនៅឡើយនោះទេ។ អត្ថប្រយោជន៍ពីការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ត្រូវបានចុះផ្សាយនៅក្នុងអត្ថបទសារព័ត៌មានក្នុងស្រុកមួយចំនួន បើទោះបីជា មិនមានការផ្សព្វផ្សាយណាមួយនៅឡើយពីផលប៉ះពាល់អវិជ្ជមាននានាដែលអាចកើតឡើងដោយសារកិច្ចព្រមព្រៀង ឬច្បាប់ថ្មីៗទាំងនេះ បើផ្អែកទៅលើផលប៉ះពាល់ទាំងរយៈពេលខ្លី និងយូរអង្វែងមកលើជីវភាពរស់នៅ សិទ្ធិមនុស្សរបស់ប្រជាជន ជាពិសេសកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច ធនធានធម្មជាតិដែលនៅសេសសល់ ព្រមទាំងផលប៉ះពាល់របស់វាដោយផ្ទាល់និងដោយប្រយោលមកលើសេដ្ឋកិច្ចនៅកម្រិតមូលដ្ឋាន ឬសេដ្ឋកិច្ចក្នុងស្រុកនៅឡើយទេ។

នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានសម្រេចប្រកាសបើកប្រទេសឡើងវិញ បន្ទាប់ពីសម្រេចគោលដៅរបស់ខ្លួនក្នុងការផ្តល់វ៉ាក់សាំងដល់ប្រជាពលរដ្ឋចំនួន ១០លាននាក់រួចរាល់។ គិតត្រឹមថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០២១ កម្ពុជាបានផ្តល់វ៉ាក់សាំងដល់ប្រជាពលរដ្ឋប្រមាណ ៨៨.០៦ភាគរយ ធៀបនឹងចំនួនប្រជាជនសរុបដែលមានចំនួនជាង ១៦លាននាក់។[1] ធុរៈកិច្ច អាជីវកម្ម និងវិស័យមួយចំនួនធំ ត្រូវបានអនុញ្ញាត្តិឱ្យបើកដំណើរការឡើងវិញជាធម្មតា។ ដោយក្នុងនោះ វិស័យទេសចរណ៍ និងកំសាន្ត (ចំពោះក្លឹបកំសាន្ត ខារ៉ាអូខេ និងរង្គសាល ឌីស្កូលតែកត្រូវបានតម្រូវឱ្យនៅបន្តបិទដំណើរការបណ្តោះអាសន្នរហូតដល់មានការជូនដំណឹងបន្ថែម) បើកដំណើរការឡើងវិញនៅគ្រឹះស្ថានអប់រំទាំងសាធារណៈ និងឯកជនជាដើម។ល។ ការបើកប្រទេសឡើងវិញ ធ្វើឡើងក្នុងគោលបំណងស្តារឡើងវិញនៅឱនភាពសេដ្ឋកិច្ចជាតិនាអំឡុងពេលវិបត្តិបណ្តាលពីការរាតត្បាតនៃជំងឺកូវីដ-១៩។

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចទទួលរងផលប៉ះពាល់អវិជ្ជមានលើផ្នែកសេដ្ឋកិច្ច និងសង្គមដែលស្តែងចេញពីការរាតត្បាតនៃជំងឺកូវីដ-១៩ មកលើសុខភាព ជីវភាពរស់នៅ ជួបប្រទះនឹងអសន្តិសុខស្បៀងបន្តធ្លាក់ទៅក្នុងរង្វង់នៃបំណុល ព្រមទាំងទទួលរងការកេងប្រវ័ញ្ចនិងរំលោភសិទ្ធិមនុស្សជាដើម។ វិបត្តិដែលស្តែងចេញពី បម្រែបម្រួលអាកាសធាតុមានជាអាទិ៍ គ្រោះទឹកជំនន់ និងរាំងស្ងួតនាអំឡុងឆ្នាំ ២០២០ និងឆ្នាំ ២០២១

បានបន្ថែមបន្ទុក និងជម្រុញឱ្យស្ថានភាពជីវភាពរស់នៅរបស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចធ្លាក់ចុះនិងដុនដាបមួយកម្រិតទៀត។

ផងដែរនោះ ការសម្រេចបិទខ្ទប់ភូមិសាស្ត្ររាជធានី-ខេត្តភ្លាមៗ បើទោះបីជា សេចក្ដីសម្រេចនេះត្រូវបានធ្វើឡើងក្នុងគោលបំណងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយក្ដី សេចក្ដីសម្រេចចិត្តនេះ បានបណ្ដាលឱ្យមានភាពច្របូកច្របល់ បង្ករមានឱ្យភាពភ័យខ្លាច និងភាពមិនប្រាកដប្រជានៃការវិវដ្ដរបស់ការរាតត្បាតនៃជំងឺកូវីដ-១៩ ក្នុងចំណោមប្រជាពលរដ្ឋទូទៅ និងកសិករដែលរស់នៅតំបន់ជនបទ។ សេចក្ដីសម្រេចពីការបិទខ្ទប់ភ្លាមៗ បានផ្ដល់ផលប៉ះពាល់ដោយផ្ទាល់ និងប្រយោលមកលើកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច។ បញ្ហាតម្លៃស្បៀងអាហារនៅលើទីផ្សារឡើងថ្លៃយ៉ាងគំហុក បណ្ដាលឱ្យកសិករ និងគ្រួសារកសិករមួយចំនួនមានបទពិសោធន៍ជួបនឹងកង្វះស្បៀងអាហារ។ កសិករមួយចំនួន មិនមានលទ្ធភាពទិញស្បៀងអាហាររក្សាទុកក្នុងអំឡុងពេលបិទខ្ទប់ ដែលការណ៍នេះ មិនរាប់បញ្ចូលនៅឡើយចំពោះការធ្លាក់ចុះជីវភាពរស់នៅពីការបាត់បង់ការងារភ្លាមៗ ដោយសារការបិទផ្អាកដំណើរការអាជីវកម្មមួយចំនួនដោយមិនបានផ្ដល់អត្ថប្រយោជន៍នានា ឬក្នុងករណីខ្លះសូម្បីតែប្រាក់ខែចុងក្រោយក៏សមាជិកគ្រួសាររបស់ពួកគាត់មិនបានទទួល។

មានការប្រើប្រាស់អំពើហិង្សា ការគម្រាមកំហែង និងការដាក់ទោសទណ្ឌទៅលើប្រជាពលរដ្ឋមួយចំនួនដែលបញ្ចេញមតិរិះគន់ទៅលើវិធាននិងការអនុវត្តច្បាប់នៅលើបណ្ដាញព័ត៌មានសង្គមជាដើម។ល។ពីសំណាក់បុគ្គលអ្នកអនុវត្តច្បាប់មួយចំនួន។ ការអនុវត្តនេះ បានធ្វើឱ្យកសិករនិងអ្នកផលិតស្បៀងអាហារមួយចំនួនមានការមិនពេញចិត្ត។ ដោយឡែក ការគាំទ្រផ្នែកសង្គមពីសំណាក់អាជ្ញាធរមូលដ្ឋាន ក្រសួងសុខាភិបាល និងរដ្ឋាភិបាលនាអំឡុងពេលបិទខ្ទប់ត្រូវបានសារទរពីសំណាក់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច បើទោះជាការគាំទ្រមានកម្រិតទាប បើធៀបទៅនឹងផលប៉ះពាល់ដែលពួកគាត់ជួបប្រទះ។

## អំពីរបាយការណ៍

របាយការណ៍ស្រាវជ្រាវស្តីពី "ផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចនៅក្នុងប្រទេសកម្ពុជា" ជាលទ្ធផលចេញពីកិច្ចសហការរវាងអង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ បណ្តាញពហុវិស័យនៃអង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍ កម្មវិធីផ្តោតទៅលើលោកខាងត្បូង (Focus on the Global South) និងតំណាងអ្នកស្រែ កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចមួយចំនួនពីសហគមន៍មូលដ្ឋាន។

សូមបញ្ជាក់ថា នេះជាលើកទីពីរហើយដែលក្រុមការងារស្រាវជ្រាវផលិតរបាយការណ៍ពីផលប៉ះពាល់ពីការរាតត្បាតនៃជំងឺកូវីដ-១៩ មកលើកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច។ របាយការណ៍ទីមួយត្រូវបានបោះពុម្ពផ្សាយនៅខែសីហា ឆ្នាំ ២០២០ ជាផ្នែកនៃគំនិតផ្តួចផ្តើមពីសមាជិកនៃសម្ព័ន្ធបងប្អូនស្រី រួមសហការជាមួយក្រុមការងារ និងស្ថាប័នដែលចូលរួមក្នុងកិច្ចការស្រាវជ្រាវនេះ។ របាយការណ៍ទីពីរនេះ ត្រូវបានរៀបចំឡើងដើម្បីធ្វើបច្ចុប្បន្នភាពពីផលប៉ះពាល់ពីការរាតត្បាតនៃកូវីដ-១៩ មកលើកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច។

### ការសិក្សាស្រាវជ្រាវនេះធ្វើឡើងជាមួយគោលបំណងបីចំបងៗ ដូចជា៖

១ ស្វែងយល់ពីផលប៉ះពាល់នៃវិបត្តិនានាដែលបណ្តាលពីការរាតត្បាតនៃជំងឺកូវីដ-១៩ មកលើកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច

២ តម្រូវការរបស់កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចក្នុងអំឡុងពេលនៃការរាតត្បាតពីជំងឺកូវីដ- ១៩ និង

៣ សំណើរ និងអនុសាសន៍ជូនទៅកាន់រដ្ឋាភិបាល ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងស្ថាប័នពាក់ព័ន្ធនានា។

## អំពីវិធីសាស្ត្រ និងកម្រិតភាព

ការសិក្សាស្រាវជ្រាវធ្វើឡើងក្នុងទម្រង់ទាំងបែបបរិមាណ និងគុណភាព។ កិច្ចសម្ភាសន៍ធ្វើឡើងតាមរយៈប្រព័ន្ធទូរស័ព្ទ។ កិច្ចសម្ភាសន៍ធ្វើជាមួយអ្នកស្រែ កសិករនិងអ្នកផលិតស្បៀអាហារខ្នាតតូច និងត្រូវបានធ្វើឡើង ពីថ្ងៃទី ១០ ខែឧសភា និងបញ្ចប់នៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០២១។ សមាជិកក្រុមការងារស្រាវជ្រាវមួយចំនួន បានចុះអង្កេតពីស្ថានភាពទូទៅដោយផ្ទាល់នៅក្នុងភូមិសាស្ត្រខេត្តកោះកុង បាត់ដំបង និងប៉ៃលិន ក្រោយការសម្ភាសន៍បានបញ្ចប់រួចរាល់។ ការចុះអង្កេតធ្វើឡើងដើម្បីស្វែងយល់បន្ថែមទៅលើស្ថានការណ៍ការវិវត្ត និងការអនុវត្តវិធាននានានៅកម្រិតមូលដ្ឋាន។ កិច្ចប្រជុំពិគ្រោះយោបល់ទៅលើរបកគំហើញពីការសិក្សាស្រាវជ្រាវត្រូវបានធ្វើឡើង ដោយមានការជួបជុំដោយផ្ទាល់ជាមួយក្រុមស្រាវជ្រាវ និងពីអ្នកចូលរួមផ្តល់សម្ភាសន៍ក្នុងខែវិច្ឆិកា ឆ្នាំ ២០២១។ កសិករនិងអ្នកផលិតស្បៀងអាហារចូលរួមក្នុងកិច្ចពិគ្រោះយោបល់ មានចំនួនជាងពាក់កណ្តាលនៃអ្នកចូលរួមផ្តល់បទសម្ភាសន៍សរុប។

តំណាងកសិករ អ្នកស្រែពីសហគមន៍មូលដ្ឋានចំនួន ៩នាក់ ចូលរួមក្នុងដំណើរការសិក្សាស្រាវជ្រាវទាំងមូលដោយគិតចាប់ពីកិច្ចពិគ្រោះយោបល់ទៅលើការបង្កើតនិងសាកល្បងកម្រងសំណួរ ចូលរួមសម្ភាសន៍ ពិនិត្យមើលទៅលើលទ្ធផលស្រាវជ្រាវ និងកិច្ចពិគ្រោះយោបល់ទៅលើលទ្ធផលបឋម និងការផ្ទៀងផ្ទាត់របាយការណ៍ជាចុងក្រោយមុនពេលបោះពុម្ព និងផ្សព្វផ្សាយជាសាធារណៈ។ និស្សិតពីមហាវិទ្យាល័យក្នុងរាជធានីភ្នំពេញ និងខេត្តមួយចំនួនបានចូលរួមស្ម័គ្រចិត្តបញ្ចូលទិន្នន័យពីកិច្ចសម្ភាសន៍។

ក្រុមការងារស្រាវជ្រាវ សម្រេចបន្តផ្តល់អាទិភាពទៅលើតំបន់ភូមិសាស្ត្រក្នុងខេត្តមួយចំនួនដែលធ្លាប់បាន សិក្សានាឆ្នាំ ២០២០ មកធ្វើការសិក្សាស្រាវជ្រាវបន្ត។ ការសិក្សាស្រាវជ្រាវធ្វើឡើងជាមួយកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ១០៤នាក់ ដោយក្នុងចំណោមពួកគាត់ ២៧នាក់ ឬស្មើនឹង ២៦ភាគរយនៃអ្នកចូលរួម ផ្តល់បទសម្ភាសន៍ មិនធ្លាប់ចូលរួមផ្តល់បទសម្ភាសន៍ក្នុងការស្រាវជ្រាវឆ្នាំ ២០២០ នោះទេ។ ការជ្រើសរើសអ្នកចូលរួមផ្តល់បទសម្ភាសន៍ថ្មី ធ្វើឡើងដោយផ្អែកទៅលើមូលហេតុចម្បងពីរដូចជា ទីមួយ គឺដើម្បីរក្សាចំនួនអ្នកចូលរួមដដែល ដោយជំនួសអវត្តមានអ្នកចូលរួមផ្តល់បទសម្ភាសន៍នាឆ្នាំមុន ជាមួយអ្នកផ្តល់បទសម្ភាសន៍ថ្មី ហើយហេតុផលទីពីរ គឺដើម្បីស្វែងយល់បន្ថែមអំពីបទពិសោធន៍ និងផលប៉ះពាល់ពីការរាតត្បាតនៃជំងឺកូវីដ-១៩ ទៅលើអ្នកផ្តល់បទសម្ភាសន៍ថ្មីៗ។ ឯកសារនិងទិន្នន័យនានាដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវនេះ ត្រូវបានត្រួតពិនិត្យនិងវិភាគយ៉ាងយកចិត្តទុកដាក់មុនពេលបញ្ចូលទៅក្នុងរបាយការណ៍។

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច ចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ មកពីចម្រុះវិស័យ។ ដូចនេះ របកគំហើញពីការសិក្សាស្រាវជ្រាវ គ្របដណ្តប់នូវបញ្ហាចម្បងៗមួយចំនួនដែលកសិករភាគច្រើនជួបប្រទះ។ របាយការណ៍ស្រាវជ្រាវនេះ មិនបានបញ្ចូលនូវទស្សនៈរបស់អាជ្ញាធរមូលដ្ឋាន ក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងរាជរដ្ឋាភិបាលនោះទេ ដោយសារកត្តាតកម្រិតភាព និងអទិភាពនៃការសិក្សាស្រាវជ្រាវ។ ដើម្បីរក្សាសុវត្ថិភាព និងព័ត៌មានឯកជនរបស់កសិករនិងអ្នកផលិស្បៀងអាហារខ្នាតតូចដែលចូលរួមផ្តល់

បទសម្ភាសន៍ ឈ្មោះ និងទិន្នន័យរបស់ពួកគាត់នៅក្នុងរបាយការណ៍ត្រូវបានតាងជំនួសដោយអក្សរកាត់ឬឈ្មោះជំនួស។

របាយការណ៍ស្រាវជ្រាវនេះ ចែកចេញជាបីផ្នែកធំៗ។ ផ្នែកទីមួយ រៀបរាប់អំពីគោលបំណងនៃការសិក្សាស្រាវជ្រាវ វិធីសាស្ត្រ និងកម្រិតភាព។ ផ្នែកទីពីរ បង្ហាញពីរបកគំហើញចម្បងៗ មានដូចជាៈ ពីបទពិសោធន៍ទទួលបានព័ត៌មានពីវិធានទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ វិធានទប់ស្កាត់ និងយន្តការគាំទ្ររបស់រដ្ឋាភិបាលចំពោះកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច ផលប៉ះពាល់វិបត្តិនានាដែលបណ្តាលពីការរាតត្បាតនៃជំងឺកូវីដ-១៩ មកលើសុខភាព ជីវភាព ការបង្ករបង្កើនផល និងការគាំទ្ររបស់រដ្ឋាភិបាល បញ្ហាវដ្តនៃបំណុល និងអន្តរាគមន៍របស់រដ្ឋាភិបាល ស្ថានភាពទន្ទ្រានដីធ្លី ធនធានធម្មជាតិ ជម្លោះដីធ្លី និងបញ្ហាការរើសអើងរំលោភសិទ្ធិមនុស្សក្នុងកម្រិតមូលដ្ឋាន។ ផ្នែកចុងក្រោយផ្តោតទៅលើតម្រូវការ សំណើរ និងអនុសាសន៍របស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចជូនរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរ ព្រមទាំងស្ថាប័នពាក់ព័ន្ធនានា។

## របកគំហើញ

### ព័ត៌មានទូទៅរបស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច




កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន១០៤នាក់ ចូលរួមផ្តល់បទសម្ភាសន៍។ ក្នុងចំណោមនោះ កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចជាស្ត្រីមានចំនួន ៤៥នាក់ ឬស្មើនឹង ៤៣.៣ភាគរយ បើធៀបទៅនឹងកសិករបុរសដែលមានចំនួន ៥៩នាក់ ឬស្មើនឹង ៥៦.៧ភាគរយ។ ពួកគាត់មានអាយុចន្លោះចាប់ពី ១៨ឆ្នាំ ទៅដល់ឬលើស ៦០ឆ្នាំ។ កសិករ និងអ្នកផលិតស្បៀងអាហារដែលចូលរួមសម្ភាសន៍មានអាយុ ៦០ឆ្នាំ ឬលើស ៦០ឆ្នាំឡើង មានចំនួន ៥២.៩ភាគរយ។ អាយុចន្លោះពី ៤០ឆ្នាំ-៥៩ឆ្នាំ មានចំនួន ២៩.៨ភាគរយ ហើយកសិករដែលមានអាយុចន្លោះពី ២៥ឆ្នាំ-៣៩ឆ្នាំ មានចំនួនតិចតួចទេ គឺមានប្រមាណ ១៧.៣ភាគរយ។

ក្រៅពីមុខរបរចម្បងធ្វើស្រែចំការ កសិករនិងអ្នកផលិតស្បៀងខ្នាតតូចមានមុខរបរបន្ទាប់បន្សំផ្សេងទៀតដូចជា ការដាំដំណាំជាលក្ខណៈគ្រួសារ ចិញ្ចឹមសត្វ (មាន់ ទា ជ្រូក គោ និងក្របី) នេសាទ ការអាស្រ័យអនុផលព្រៃឈើ លក់ពលកម្មប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍ ជាកម្មករក្នុងចំការដំណាំកសិឧស្សាហកម្មធំៗ កម្មករក្នុងរោងចក្រ រត់ម៉ូតូឌុប ស៊ីឈ្នួលធ្វើផ្ទះ ឬធ្វើជាកម្មករសំណង់ជាដើម។ ក្រៅពីប្រភពចំណូលចម្បងៗខាងលើ បញ្ញើរសាច់ប្រាក់ពីកូនឬសមាជិកគ្រួសារក៏ជាប្រភពចំណូលដ៏សំខាន់សម្រាប់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច។

កសិករដែលចូលរួមផ្តល់បទសម្ភាសន៍ក្នុងដំណើរការស្រាវជ្រាវនេះ ក៏មានតួនាទីផ្សេងៗនៅក្នុងសហគមន៍ដូចជា ជាសមាជិក តំណាងឬអ្នកសម្របសម្រួលសហគមន៍មូលដ្ឋាន និងបណ្តាញមួយចំនួនរួមទាំង បណ្តាញឬសហគមន៍ដីធ្លី ការពារព្រៃឈើនិងអភិរក្សធនធានធម្មជាតិ ជាសមាជិកបណ្តាញឬក្រុម

កសិករ អ្នកនេសាទ និងអ្នកជាសមាជិកក្នុងភូមិជាដើម។ល។ ពួកគាត់មានទីលំនៅក្នុងរាជធានី និងខេត្តមួយចំនួនដូចជា ខេត្តបាត់ដំបង កំពង់ឆ្នាំង ប៉ៃលិន ពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ កំពង់ស្ពឺ កំពង់ចាម កំពង់ធំ តាកែវ ព្រៃវែង ស្វាយរៀង ព្រះសីហនុ កំពត កោះកុង កណ្ដាល និងរាជធានីភ្នំពេញ។ កសិករចូលរួមពីខេត្តចំនួនប្រាំមានចំនួនច្រើនជាងខេត្តដទៃនៅក្នុងកិច្ចសម្ភាសន៍។ ខេត្តទាំងប្រាំមានដូចជា ទីមួយខេត្តបាត់ដំបង ដែលមានចំនួនអ្នកចូលរួម ២០នាក់ ឬស្មើនឹង ១៩.២ភាគរយ ទីពីរខេត្តឧត្តរមានជ័យ មានចំនួនអ្នកចូលរួម ១២នាក់ ឬស្មើនឹង ១១.៥ភាគរយ ទីបីខេត្តពោធិ៍សាត់ មានចំនួន ១០នាក់ ឬស្មើនឹង ៩.៦ភាគរយ និងពីរខេត្តទៀតដែលមានចំនួនដូចគ្នាគឺខេត្តកំពង់ឆ្នាំង ៩នាក់ (៨.៧ភាគរយ) និងខេត្តប៉ៃលិន ៩នាក់ (៨.៧ភាគរយ)។ កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចមានចំនួនសមាជិកគ្រួសារចន្លោះពី ២នាក់ដល់ ១៣នាក់ដែលរស់នៅក្នុងបន្ទុករបស់ពួកគេ។ ១ភាគ៤ នៃកសិករសរុប មានសមាជិកគ្រួសារចំនួន ៨នាក់ក្នុងមួយគ្រួសារ ហើយបួនគ្រួសារផ្សេងទៀត មានសមាជិកចន្លោះពី ១០នាក់ទៅ ១៣នាក់ ក្នុងមួយគ្រួសារ។




*ផែនទីរាជធានី ខេត្តគោលដៅក្នុងការសម្ភាសន៍*

## ១. បទពិសោធពីការទទួលបានព័ត៌មានពីវិធានទប់ស្កាត់ការរីរាលដាលនៃ និង យន្តការគាំទ្រនានារបស់រដ្ឋាភិបាល

### ១.១. ការផ្សព្វផ្សាយព័ត៌មាន ពីវិធានទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍




*តារាងបង្ហាញពីបទពិសោធន៍របស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចទៅលើក្នុងការ ទទួលបានព័ត៌មានពីវិធានទប់ស្កាត់ការរីករាលដាលជំងឺកូវដី-១៩*

ជុំវិញការផ្សព្វផ្សាយអំពីការអនុវត្តវិធានសុខាភិបាល វិធានរដ្ឋបាល និងវិធានផ្សេងៗដើម្បីការពារ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ពីសំណាក់ក្រសួងសុខាភិបាល ក្រសួងពាក់ព័ន្ធមួយចំនួន និង អាជ្ញាធរមូលដ្ឋាន កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច មានបទពិសោធន៍ និងការទទួលបានព័ត៌មានផ្សេងៗគ្នា។

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៩៦នាក់ (៩២.៣ភាគរយ) ធ្លាប់ទទួលបានព័ត៌មានពីវិធានបង្ការជំងឺកូវីដ-១៩ ឬវិធានបីកុំ បីការពារ ដែលមានដូចជា ការលាងសម្អាតដៃជាប្រចាំ ពាក់ម៉ាស់ រក្សាគម្លាត និងមិនទៅកន្លែងចង្អៀតបិទជិតពីសំណាក់អាជ្ញាធរមូលដ្ឋាន។ ចំពោះព័ត៌មានស្តីអំពីរោគសញ្ញានៃជំងឺកូវីដ-១៩ កសិករចំនួន ២២នាក់ (២១.២ភាគរយ) មិនធ្លាប់ទទួលបានព័ត៌មាននេះទេ បើធៀបទៅនឹងកសិករចំនួន ៨០នាក់ (៧៦.៩ភាគរយ) ដែលធ្លាប់ទទួលបានព័ត៌មានពីសំណាក់អាជ្ញាធរមូលដ្ឋាន។

កសិករចំនួន ៤៦នាក់ (៤៤.២ភាគរយ) មិនទទួលបានព័ត៌មានពីចំនួនករណីកូវីដ-១៩ (មានដូចជា ចំនួនករណីអ្នកមានវិជ្ជមាន អ្នកជាសះស្បើយ និងចំនួនអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩) ផ្ទុយពីកសិករចំនួន ៤៩នាក់ (៤៧.១ភាគរយ) ដែលបានទទួលព័ត៌មាននេះ។ កសិករចំនួន ៣៧.៥ភាគរយ មិន

ទទួលបានព័ត៌មានអំពីនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់គ្រប់គ្រងថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ (ឬការព្យាបាលតាមផ្ទះ) ថ្វីបើ កសិករចំនួន ៣៨.៥ភាគរយ បានទទួលព័ត៌មានជុំវិញវិធាននេះ។

ការផ្សព្វផ្សាយព័ត៌មានពីរដ្ឋាភិបាល ក្រសួង និងអាជ្ញាធរមូលដ្ឋានទៅលើវិធានការពារ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ត្រូវបានកត់សម្គាល់ថា មានលក្ខណៈប្រសើរជាងឆ្នាំ ២០២០។ រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន បន្តប្រើប្រាស់វិធីសាស្ត្រចម្រុះក្នុងការផ្សព្វផ្សាយព័ត៌មាន ដោយព្យាយាមគ្របដណ្តប់តំបន់ដាច់ស្រយាល។ ប៉ុន្តែ ការផ្សព្វផ្សាយហាក់នៅមានកង្វះខាតនៅឡើយ ឧទាហរណ៍ ការផ្សព្វផ្សាយព័ត៌មានជុំវិញការតាក់តែងនិងអនុម័តច្បាប់ស្តីពី វិធានទប់ស្កាត់ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងយន្តការឧបត្ថម្ភគាំទ្រផ្នែកសង្គម និងទៅតាមវិស័យជាដើម នៅមិនមានភាពទូលំទូលាយ ឬធ្វើឡើងភ្លាមៗ បើធៀបទៅនឹងសេចក្តីសម្រេចអនុវត្តវិធានរដ្ឋបាលមួយចំនួន។ ក្រៅពីការលើកឡើងនៅចំណុចខ្វះខាតនេះ បញ្ហាការផ្សព្វផ្សាយព័ត៌មានមិនទាន់មានភាពទូលំទូលាយពីរសំណាក់ដ្ឋាភិបាលដោយផ្ទាល់នៅឡើយ ដោយសារកសិករភាគច្រើនបន្តទទួលបានព័ត៌មានពីអ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមទៅវិញ ដូចជា Facebook Twitter Youtube ឬ Tik Tok ជាដើម។

## ១.២. ការផ្សព្វផ្សាយព័ត៌មានអំពីយន្តការគាំទ្រនានារបស់រដ្ឋាភិបាល

កសិករចំនួន ៧៨នាក់ ឬស្មើនឹង ៧៥ភាគរយ ដឹងពីកម្មវិធីផ្តល់សាច់ប្រាក់ដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះក្នុងវិបត្តិជំងឺកូវីដ-១៩ តាមរយៈប័ណ្ណក្រីក្រពីសំណាក់រដ្ឋាភិបាល នៅពេលដែលកសិករចំនួន ២៦នាក់ ស្មើឬនឹង ២៥ភាគរយ មិនបានដឹងអំពីកម្មវិធីនេះ។ ដោយឡែកកសិករចំនួន ៤៤.២ភាគរយ មិនបានដឹង អំពីការគាំទ្រអាហារសម្រាប់ប្រជាជនក្នុងអំឡុងពេលធ្វើចត្តាឡីស័កទាំងនៅមណ្ឌលចត្តាឡីស័ក ឬនៅផ្ទះ នៅពេលដែលកសិករចំនួន ៥៥.៨ភាគរយផ្សេងទៀតបានដឹងអំពីការគាំទ្រនេះ។




*តារាងបង្ហាញពីការទទួលបានព័ត៌មានរបស់កសិករ*
*ទៅលើកម្មវិធីផ្តល់សាច់ដល់គ្រួសារក្រីក្រ ក្នុងវិបត្តិជំងឺកូវីដ-១៩*

កសិករចំនួន ៧៨.៨ភាគរយ មិនបានដឹងពីកម្មវិធីឥណទានគាំទ្រដល់សហគ្រិនកសិកម្មខ្នាតតូច និងមធ្យមជាមួយទឹកប្រាក់ ៥០លានដុល្លារ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដោយអត្រាការប្រាក់ទាប បើធៀបទៅនឹងកសិករចំនួនត្រឹមតែ ១៨.៣ភាគរយ បានដឹងពីការគាំទ្រនេះ។ កសិករច្រើនលើសលុប (៨៣.៧ភាគរយ) មិនបានដឹងឬទទួលបានព័ត៌មានអំពីការជួយប្រមូលទិញផលិតផលកសិកម្មរបស់កសិករខ្នាតតូចនិងមធ្យមក្នុងតំលៃសមរម្យ មានតែកសិករមួយចំនួនតូច (១២.៥ភាគរយ) បានដឹង។




*កម្មវិធីឥណទានគាំទ្រដល់សហគ្រិន កសិកម្មខ្នាតតូច និងមធ្យម*




*ការជួយប្រមូលទិញផលិតផលកសិកម្មរបស់ កសិករខ្នាតតូច និងមធ្យមក្នុងតំលៃសមរម្យ*




*អន្តរាគមន៍បន្ថែមរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុដើម្បីគាំពារដល់អតិថិជន*

កសិករ៦៦.៣ភាគរយមិនបានដឹងអំពីអន្តរាគមន៍បន្ថែមរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដើម្បីគាំពារដល់អតិថិជន ក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ ដែលត្រូវបានចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០២១ នៅក្នុងសេចក្តីថ្លែងការណ៍រួមរបស់សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុនៅកម្ពុជាកន្លងមកទេ។ មានតែ ៣១.៧ ភាគរយនៃកសិករដែលផ្តល់បទសម្ភាសន៍បានដឹង។

## ១.៣ ព័ត៌មានជុំវិញការបង្កើតការអនុម័ត ឬការដាក់ចេញឱ្យប្រើប្រាស់ច្បាប់ អនុក្រឹត្យ ព្រមទាំងវិធានមួយចំនួនរបស់រដ្ឋាភិបាលដើម្បីទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ-១៩៖

តារាងខាងក្រោម បង្ហាញពីចំនួនភាគរយដែលកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច ឆ្លើយតប ជុំវិញការទទួលបានព័ត៌មានស្តីពីការបង្កើត ការអនុម័តឬការដាក់ចេញឱ្យអនុវត្តន៍ច្បាប់ អនុក្រឹត្យ ព្រមទាំង វិធានឆ្លើយតបមួយចំនួនរបស់រដ្ឋាភិបាលចំពោះជំងឺកូវីដ-១៩។

| ព័ត៌មានជុំវិញ ការបង្កើត ការអនុម័ត ការអនុវត្តនូវច្បាប់ អនុក្រឹត្យ វិធានឆ្លើយតបមួយចំនួន | បានដឹង | មិនបានដឹង | សូមមិនឆ្លើយ |
|---|---|---|---|
| ១. សេចក្តីជូនដំណឹងស្តីពី វិធានការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងឱកាសឈប់សម្រាកពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ | ២២.១ភាគរយ | ៧៧.៩ភាគរយ | ០ភាគរយ |
| ២. អនុក្រឹត្យស្តីពី វិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាច សាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត | ៤៦.២ភាគរយ | ៥២.៩ភាគរយ | ១.០ភាគរយ |
| ៣. ច្បាប់ស្តីពី វិធានទប់ស្កាត់ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត | ៥៣.៨ភាគរយ | ៤៦.២ ភាគរយ | ០ភាគរយ |
| ៤. អនុក្រឹត្យស្តីពីកាតព្វកិច្ចក្នុងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ | ៦០.៦ភាគរយ | ៣៨.៥ភាគរយ | ១ភាគរយ |

| | | | |
|---|---|---|---|
| ៥. សេចក្តីសម្រេចស្តីពី ការពិន័យអន្តរការណ៍ចំពោះបុគ្គលដែលមិនគោរពដោយចេតនា វិធានការរដ្ឋបាលក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត | ៧៦.៩ភាគរយ | ២១.២ភាគរយ | ១.៩ភាគរយ |
| ៦. សេចក្តីសម្រេចស្តីពី ការហាមឃាត់ការធ្វើដំណើរ និងការបិទរមណីយដ្ឋានទេសចរណ៍ទូទាំងប្រទេសជាបណ្តោះអាសន្នដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺ កូវីដ-១៩ | ៨៥.៦ភាគរយ | ១៣.៥ភាគរយ | ១ភាគរយ |
| ៧. សេចក្តីសម្រេចស្តីពីការបិទខ្ទប់ភូមិសាស្រ្តរាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ | ៨៨.៥ភាគរយ | ១១.៥ភាគរយ | ១ភាគរយ |

កសិករ ៧៧.៩ភាគរយ មិនបានទទួលព័ត៌មានពីវិធានការបង្ការ និងការទប់ស្កាត់ការរីករាលដាលនៃជំងឺ កូវីដ-១៩ ក្នុងឱកាសឈប់សម្រាកពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិឆ្នាំ ២០២១ ហើយកសិករភាគតិច ឬចំនួន ២២.១ភាគរយដែលបានទទួលព័ត៌មានពីវិធានខាងលើ។ កសិករពាក់កណ្តាលមិនបានដឹងអំពី អនុក្រឹត្យស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។ កសិករជាង ៤០ភាគរយ មិនបានទទួលព័ត៌មានពីច្បាប់ស្តីពីវិធានទប់ស្កាត់ជំងឺកូវីដ-១៩។ ដោយឡែក ៦០.៦ភាគរយ បានទទួលព័ត៌មានអំពីអនុក្រឹត្យស្តីពីកាតព្វកិច្ចក្នុងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩។ កសិករចំនួន ៧៦.៩ភាគរយ បានដឹងពីសេចក្តីសម្រេចស្តីពី ការពិន័យអន្តរការណ៍ចំពោះបុគ្គលដែលមិនគោរពដោយចេតនា វិធានរដ្ឋបាលក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។ កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច ចំនួនច្រើន ឬ ៨៥.៦ភាគរយ បានទទួលព័ត៌មានអំពីសេចក្តីសម្រេចស្តីពី ការហាមឃាត់ការធ្វើដំណើរ និងការបិទរមណីដ្ឋានទេសចរណ៍ទូទាំងប្រទេសជាបណ្តោះអាសន្ន។ រីឯ កសិករចំនួន ៨៨.៥ភាគរយ បានដឹងព័ត៌មានអំពីសេចក្តីសម្រេចស្តីពីការបិទខ្ទប់ភូមិសាស្រ្តរាជធានីភ្នំពេញ និងក្រុងតាខ្មៅដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

## ២. បទពិសោធន៍ និងទស្សនៈរបស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច នៅលើវិធាន និងការអនុវត្តរបស់អាជ្ញាធរមូលដ្ឋាន ក្រសួងនិងមន្ទីរ ព្រមទាំងស្ថាប័នពាក់ព័ន្ធ

> “
> *ការធ្វើពិធីបុណ្យប្រពៃណី គួរត្រូវបានលើកលែងក្នុងករណីខ្លះ ដោយវាជាលក្ខខណ្ឌចាំបាច់។ ក្នុងករណីខ្លះ ប្រសិនបើ មិនបានធ្វើ ឬជួបជុំគ្នាតាមទំនៀមទម្លាប់ ឬអបិយជំនឿនោះទេ វាអាចធ្វើអោយសមាជិកសហគមន៍ស្លាប់ ឬខ្មោចកាច់ ព្រោះមានការបន់ស្រន់អារក្ស អ្នកតា។ ដូចពាក្យចាស់ៗពីបុរាណថា ពេលឈឺយកដំរីមកបន់ពេលស្រន់យកពងមាន់មកសែន*
>
> *ទស្សនៈរបស់ស្ត្រីកសិករមួយរូប ចំពោះសេចក្តីសម្រេចរឹតត្បិតការជួបជុំបែបសាសនានាអំឡុងពេលការរាតត្បាតនៃជំងឺកូវីដ-១៩*
> ”

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច បានលើកឡើងពីការយល់ឃើញផ្សេងៗគ្នា ទៅលើការរឹតត្បិតការជួបជុំក្នុងអំឡុងពេលនៃការរាតត្បាតពីជំងឺកូវីដ-១៩។ កសិករមួយចំនួន គាំទ្រចំពោះវិធានរឹតបណ្តឹងទាំងនោះដោយអះអាងថា វាជាការល្អប្រសើរដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងការពារគ្រោះថ្នាក់ ដែលបណ្តាលពីការរាតត្បាតពីជំងឺកូវីដ-១៩ កាន់តែខ្លាំងឡើងៗនៅក្នុងសហគមន៍ ហើយការដាក់ចេញនូវវិធាននានា អាចកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើអាយុជីវិតរបស់សមាជិក ឬក្រុមគ្រួសារក្នុងសហគមន៍ និងប្រជាពលរដ្ឋទូទាំងប្រទេស។ បើទោះជាមានការលើកឡើងយ៉ាងនេះក្តី ក្នុងចំណោមកសិករដែលគាំទ្រចំពោះយន្តការរឹតបណ្តឹងនេះ កសិករមួយចំនួនក៏បានលើកឡើងអំពីបញ្ហាប្រឈម និងផលប៉ះពាល់នានាផងដែរ ដោយក្នុងនោះរួមមាន បញ្ហាការបាត់បង់ចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ បញ្ហាកង្វះស្បៀង និងបញ្ហាប្រឈមធ្ងន់ធ្ងរ ពិសេសមិនមានលទ្ធភាពសងបំណុលត្រឡប់ទៅកាន់ធនាគារពាណិជ្ជ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ និងបញ្ហាការកើនឡើងនៃបំណុលគ្រួសារជាដើម។

ដោយឡែក កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចមួយចំនួនទៀត បង្ហាញពីការមិនពេញចិត្តរបស់ពួកគាត់ចំពោះវិធានការរឹតបណ្តឹងខាងលើ ដោយលើកឡើងថា វាមានលក្ខណៈធ្ងន់ធ្ងរខ្លាំងហើយផ្តល់ផលប៉ះពាល់ដល់សិទ្ធិសេរីភាពទាំងការជួបជុំ ការប្រមូលផ្តុំនិងតស៊ូមតិ សិទ្ធិទទួលបានការប្រកបរបរចិញ្ចឹមជីវិត និងសកម្មភាពការពារព្រៃឈើ នេសាទ និងធនធានធម្មជាតិជាដើម។

កសិករមួយចំនួន លើកឡើងពីការធ្លាក់ចុះនៃទំនាក់ទំនងនិងសាមគ្គីភាពនៅក្នុងសហគមន៍ និងសង្គម ដោយសារមនុស្សម្នាក់ៗមានការខ្លាចរអាគ្នា ដែលជាហេតុបណ្តាលឱ្យមានការរើសអើងមកលើអ្នកដែលត្រូវបានសង្ស័យថាមាន ឬមកលើអ្នកជំងឺនិងក្រុមគ្រួសារអ្នកមានជំងឺកូវីដ-១៩។



*រូបភាពបង្ហាញពីទីតាំងត្រួតពិនិត្យសុខភាពមេរោគកូវីដ-១៩ ព្រំប្រទល់ខេត្តបាត់ដំបង និងខេត្តប៉ៃលិន*

ជាក់ស្តែង កសិករមួយចំនួន ធ្លាប់មានបទពិសោធន៍ទទួលរងការរើសអើងពីអ្នកភូមិ និងអាជ្ញាធរនៅភូមិដទៃ ដោយអ្នកទាំងនោះបដិសេធមិនលក់ម្ហូបអាហារឬទំនិញប្រើប្រាស់ប្រចាំថ្ងៃឱ្យពួកគាត់ ឬមិនឱ្យពួកគាត់ចូលភូមិដោយសារសង្ស័យថាភូមិរបស់ពួកគាត់មានអ្នកមានវិជ្ជមានជំងឺកូវីដ-១៩ ច្រើនគ្រួសារ។

ថ្វីបើ កសិករភាគច្រើនយល់ស្របទៅលើវិធានការណែនាំស្តីពី ការផ្អាកពិធីអាពាហ៍ពិពាហ៍ ពិធីជួបជុំបែបសាសនា និងការប្រមូលផ្តុំតាមបែបប្រពៃណី កសិករមួយចំនួនតូចលើកឡើងពីបញ្ហាការខាតបង់ប្រាក់កាសរបស់ពួកគាត់ដែលបានចំណាយទៅលើការត្រៀមរៀបចំកម្មវិធីទាំងនោះ ជាពិសេសកម្មវិធីរៀបអាពាហ៍ពិពាហ៍របស់សមាជិកគ្រួសារ។ បញ្ហាការបាត់បង់ប្រពៃណី ការបន់ស្រន់សែនព្រេនខាងអបិយជំនឿត្រូវបានលើកឡើងផងដែរ ពីសំណាក់កសិករដែលមានអត្តសញ្ញាណជាជនជាតិដើមភាគតិច។ ពួកគាត់ថា ការរឹតត្បិតនេះ អាចធ្វើឱ្យប៉ះពាល់ដល់ជំនឿ និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ គាត់បង្ហាញក្តីបារម្ភថា ការមិនគោរពទៅតាមទំនៀមទម្លាប់ អាចនឹងបណ្តាលឱ្យមានការបាត់បង់អាយុជីវិតសមាជិកនៅក្នុងសហគមន៍របស់ពួកគាត់ដែលបទពិសោធន៍នេះធ្លាប់កើតមាននៅក្នុងសហគមន៍។

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច យល់ស្របទៅលើសេចក្តីសម្រេចរបស់រដ្ឋាភិបាលស្តីពី ការហាមឃាត់ការធ្វើដំណើរ និងការបិទរមណីដ្ឋានទេសចរណ៍នៅទូទាំងប្រទេស។ ស្របគ្នាជាមួយនឹងការយល់ស្របទៅលើវិធាននេះ ផលប៉ះពាល់អវិជ្ជមានមួយចំនួនបានផ្តល់មកលើកសិករដែលមានចំណូលពីមុខរបរបន្ទាប់បន្សំដូចជា អ្នកលក់ដូរតូចតាចនៅក្នុងតំបន់ទេសចរណ៍ ហើយជាក់ស្តែង ការបិទកន្លែងកន្លែងទាំងនេះបានធ្វើឱ្យពួកគាត់បាត់បង់ប្រាក់ចំណូលប្រចាំថ្ងៃ និងមិនមានលទ្ធភាពសងបំណុលធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ។ ចំពោះការអនុវត្តវិធានបិទខ្ទប់ឬផ្អាកដំណើរការក្នុងតំបន់ទេសចរណ៍ទៀតសោត មិនបានផ្តល់ពេលវេលាគ្រប់គ្រាន់សមស្របសម្រាប់ឱ្យពួកគាត់បានត្រៀមខ្លួនជាមុន។

កសិករមួយចំនួនធំ បង្ហាញក្តីបារម្ភ និងសម្តែងនូវការមិនពេញចិត្តមួយចំនួនចំពោះការតាក់តែងនិងអនុម័តច្បាប់ស្តីពី "វិធានទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត" ដោយលើកឡើងថា ច្បាប់នេះមិនគួរត្រូវបានអនុម័តក្នុងកាលៈទេសៈនេះទេ។

ពួកគាត់បានលើកឡើងថា ដំណើរការតាក់តែង និងអនុម័តច្បាប់នេះត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័ស ហើយមិនបានបញ្ចូលកិច្ចពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាសាធារណៈ ព្រមជាមួយការកំណត់ទោសទណ្ឌ និងការផាកពិន័យដែលកម្រិតធ្ងន់ ហើយអាចបន្ថែមបន្ទុកដល់ប្រជាពលរដ្ឋ។ ពាក្យពេជន៍មួយចំនួនដែលប្រើប្រាស់ក្នុងច្បាប់នេះ មានភាពស្មុគស្មាញ សម្រាប់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច។ ការណ៍នេះអាចបណ្តាលឱ្យពួកគាត់ប្រឈមទៅនឹងទោសទណ្ឌ។ ច្បាប់ខាងលើនេះមានចរិតលក្ខណៈតឹងរឹង និងហាក់មិនបានពិចារណា អំពីលទ្ធភាពរបស់ប្រជាពលរដ្ឋជាពិសេសកសិករក្នុងការចូលរួមអនុវត្តវិធានការពារខ្លួន។ ជាក់ស្តែងការកំណត់ដែលមានចែងក្នុងច្បាប់តម្រូវឱ្យប្រជាពលរដ្ឋពាក់ម៉ាស់ និងប្រើប្រាស់សម្ភារការពារខ្លួន ដោយការទទួលខុសត្រូវក្នុងការទិញសម្ភារទាំងនោះ គឺជាបន្ទុករួចជាស្រេចរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះ ក៏អាចបង្កើនបន្ទុកផ្នែកស្មារតីដល់កសិករដោយសារភាពភ័យខ្លាចទាំងទៅលើ បញ្ហាប្រឈមនឹងទោសទណ្ឌផង និងភ័យខ្លាចចំពោះការឆ្លងជំងឺកូវីដ-១៩ផង។

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច លើកឡើងនូវក្តីបារម្ភទៅលើការសម្រេចបិទខ្ទប់ភូមិសាស្ត្រ រាជធានីភ្នំពេញ និងក្រុងតាខ្មៅដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ គឺជាបទបញ្ជាឬសេចក្តីសម្រេចរបស់រដ្ឋាភិបាល។ នាអំឡុងពេលនៃការអនុវត្តវិធានបិទខ្ទប់នេះ មានក៏លើកឡើងអំពីព្រឹត្តិការណ៍មួយចំនួនដែលមានការចាប់ឃុំខ្លួនមនុស្សមួយចំនួនភ្លាមៗ ដោយផ្អែកលើការមិនអនុវត្តទៅតាមវិធានរដ្ឋបាលដែលបានដាក់ចេញដោយរដ្ឋាភិបាល។ ស្រដៀងគ្នាទៅនឹងការចេញច្បាប់ស្តីពី វិធានការការពារជំងឺកូវីដ-១៩ វិធាននេះត្រូវបានសម្រេច និងដាក់ឱ្យអនុវត្តន៍ ដោយមិនមានការជូនដំណឹងជាមុន ឬទុករយៈពេលមួយសមស្របសម្រាប់ប្រជាពលរដ្ឋ។ តួយ៉ាងដូចជាប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ភូមិសាស្ត្របិទខ្ទប់ទាំងនោះ មិនបានត្រៀមស្បៀងអាហារ និងថ្នាំសង្កូវបម្រុងទុកមុន។ កសិករជាច្រើននាក់យល់ឃើញថា សេចក្តីសម្រេចនេះមានលក្ខណៈចាប់បង្ខំ ដោយមិនបើកឱកាសសម្រាប់ការចរចា ឬផ្តល់ការលើកលែងចំពោះអ្នកមានមុខរបរតូចតាចដែលរកចំណូលពីមួយថ្ងៃទៅមួយថ្ងៃ។




*រូបភាពបង្ហាញពីការបិទខ្ទប់ផ្សារមូលដ្ឋាន ក្នុងរាជធានីភ្នំពេញ*

## ៣. ផលប៉ះពាល់ពីការរាតត្បាតនៃជំងឺកូវីដ-១៩ មកលើសុខភាពកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច

> *ពេលខ្ញុំនៅមណ្ឌលចត្តាឡីស័ក ខ្ញុំបានលឺគេនិយាយថា មានការឧបត្ថម្ភសាច់ប្រាក់ចំនួន ២ម៉ឺនរៀលសម្រាប់ម្នាក់ ក្នុងមួយថ្ងៃ។ ប៉ុន្តែ ខ្ញុំមិនបានទទួលប្រាក់នោះទេសូម្បីមួយរយរៀល។ ហើយគេ (អ្នកគ្រប់គ្រងមណ្ឌលចត្តាឡីស័ក) ចង់ទុកខ្ញុំនៅក្នុងមណ្ឌលនោះ ១៦ថ្ងៃ ដែលវាលើសទៅនឹងការកំណត់នៃការធ្វើចត្តាឡីស័ក បើតាមព័ត៌មានដែលខ្ញុំបានស្តាប់។ ខ្ញុំបានតវ៉ាឱ្យដាក់ខ្ញុំត្រឹមតែ ១៤ថ្ងៃ។ មណ្ឌលផ្តល់អាហារ ៣ពេល ប៉ុន្តែមានភាពយឺតយ៉ាវ ឧទាហរណ៍ អាហារពេលព្រឹក គេផ្តល់ឱ្យនៅម៉ោង ១០ព្រឹក ហើយអាហារថ្ងៃត្រង់គេផ្តល់ឱ្យនៅម៉ោងប្រមាណ ២ ឬ ៣រសៀល។*
>
> *សម្តីកសិករម្នាក់ដែលមានបទពិសោធក្នុងមណ្ឌលចត្តាឡីស័កមួយកន្លែងក្នុងខេត្តប៉ៃលិន។*

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៧៧.៩ភាគរយ មិនបានទទួលការគាំទ្រនូវសម្ភារការពារខ្លួន ដូចជា ម៉ាស់ អាល់កុល ឬសាប៊ូលាងដៃពីរដ្ឋាភិបាល ឬអាជ្ញាធរមូលដ្ឋាននោះទេ បើធៀបទៅនឹងកសិករចំនួន ២០.២ភាគរយដែលបានទទួលការគាំទ្រសម្ភារការពារខ្លួន។ ការចំណាយទៅលើសម្ភារការពារខ្លួនក្នុងបរិបទដ៏ពិបាកនេះ ជាបន្ទុករបស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច។ ហើយការចំណាយទៅលើសម្ភារការពារខ្លួន វាអាចផ្គត់ផ្គង់ទៅលើការចំណាយម្ហូបអាហារប្រចាំថ្ងៃ។




*តារាងបង្ហាញអំពីបទពិសោធន៍នៃការធ្វើចត្តាឡីស័ករបស់អ្នកផ្តល់បទសម្ភាសន៍ និងគ្រួសារ*

កសិករចំនួន ៨៨.៥ភាគរយ មិនធ្លាប់មានបទពិសោធដោយផ្ទាល់ ឬមានសមាជិកគ្រួសារដែលបានធ្វើ ចត្តាឡីស័កក្នុងអំឡុងពេលនៃការស្រាវជ្រាវ បើធៀបទៅនឹងកសិករចំនួន ១១.៥ភាគរយ ដែលធ្លាប់បានឆ្លងកាត់បទពិសោធន៍ធ្វើចត្តាឡីស័ក ហើយក្នុងចំណោមកសិករឬសមាជិកគ្រួសារពួកគេដែលមានបទពិសោធន៍ធ្វើចត្តាឡីស័ក កសិករមួយចំនួនតូច បានទទួលការគាំទ្រក្នុងអំឡុងពេលនោះ។ ការគាំទ្រទាំងនោះមានដូចជា អាហារ ៣ពេល អង្ករចន្លោះពី ១០គីឡូក្រាម ទៅ ៣០គីឡូក្រាម មី ១កេស ត្រីខកំប៉ុង ២យួរ ម៉ាស់ ១ប្រអប់ អាល់កុល ១ដប លុយ ៣០ម៉ឺនរៀល ឬស្មើនឹង ៧៥ដុល្លារសម្រាប់មួយគ្រួសារ។ ការគាំទ្រជាសាច់ប្រាក់មិនផ្តល់ដល់គ្រប់គ្រួសារ ឬគ្រប់ពេលនោះទេ តួយ៉ាង កសិករឬគ្រួសាររបស់កសិករខ្លះមិនទទួលបានការគាំទ្រសាច់ប្រាក់ដែលបានរៀបរាប់ខាងលើ ហើយក៏មានកសិករមួយចំនួនទៀត មិនបានទទួលការគាំទ្រអ្វីសោះនៅអំឡុងពេលធ្វើចត្តាឡីស័កនៅមណ្ឌលដែលរៀបចំដោយរដ្ឋ។

មានការលើកឡើងពីមន្ទិលមួយចំនួនទៅលើប្រសិទ្ធិភាព និងផលប៉ះពាល់អវិជ្ជមានភ្លាមៗ និងរយៈពេលយូរអង្វែងពីវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ពីសំណាក់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច។ កសិករមួយចំនួនមានបទពិសោធន៍ជួបប្រទះបញ្ហាក្តៅខ្លួន ឈឺចាប់សាច់ដុំ បញ្ហាអាលាក់ស៊ីស្បែក និងអាការៈមិនប្រក្រតីមួយចំនួនទៀតបន្ទាប់ពីទទួលវ៉ាក់សាំង។ កសិករមួយចំនួនទៀត មានសុខភាពធម្មតាបន្ទាប់ពីចាក់វ៉ាក់សាំង។ ក៏ប៉ុន្តែ សំណួរជាច្រើនត្រូវបានលើកឡើងជុំវិញប្រសិទ្ធិភាពរបស់វ៉ាក់សាំង ជម្រើស និងសេចក្តីសម្រេចចិត្តរបស់ពួកគាត់ក្នុងការទទួលវ៉ាក់សាំង ព្រមទាំងក្តីបារម្ភចំពោះផលប៉ះពាល់របស់វាមកលើអាយុជីវិត និងប្រព័ន្ធសុខភាពក្នុងរាងកាយរបស់ពួកគាត់។ កសិករមួយចំនួន រិះគន់ចំពោះការដាក់កំហិតដែលតម្រូវឱ្យពួកគាត់ត្រូវតែចាក់វ៉ាក់សាំងដែលការណ៍នេះគឺត្រូវធ្វើឡើងដោយការស្ម័គ្រចិត្ត។

កសិករម្នាក់មានករណីវិជ្ជមានជំងឺកូវីដ-១៩។ គាត់ត្រូវបានអនុញ្ញាតិឱ្យសម្រាកព្យាបាលនៅផ្ទះ។ ថ្វីបើ វិធានសុខាភិបាលរបស់រដ្ឋាភិបាលចំពោះការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ទទួលបានការកោតសសើរពីសំណាក់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចភាគច្រើនក្តី ក្នុងចំណោមនោះ ពួកគេមួយចំនួនក៏បានបង្ហាញនូវភាពមិនពេញចិត្តចំពោះការទៅទទួល និងប្រើប្រាស់សេវាសុខភាពនាអំឡុងពេលពីការរាតត្បាតនៃជំងឺកូវីដ-១៩ ថាមិនមានការយកចិត្តទុកដាក់ មានការរើសអើង និងទុកឱ្យអ្នកជំងឺស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដល់អាយុជីវិត ដោយសារការបារម្ភ និងមានការភ័យខ្លាចខ្លាំងចំពោះការឆ្លងជំងឺកូវីដ-១៩។ កសិករមួយចំនួនតូច មានបទពិសោធន៍មិនទទួលបានអត្ថប្រយោជន៍ ឬការទូទាត់នៅពេលទៅប្រើប្រាស់សេវាថៃទាំ និងព្យាបាលពីការប្រើប្រាស់ប័ណ្ណបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នាអំឡុងពេលនៃការរាតត្បាតពីជំងឺកូវីដ-១៩។ពួកគាត់ត្រូវបានតម្រូវឱ្យបង់ប្រាក់សម្រាប់ការសម្រាកព្យាបាលនៅពេលទៅប្រើប្រាស់សេវាទាំងនៅមន្ទីរពេទ្យរដ្ឋ និងមន្ទីរពេទ្យឬគ្លីនីកឯកជន។ បន្ថែមទៅលើបញ្ហាមិនទទួលបានអត្ថប្រយោជន៍ ឬការទូទាត់ពីការប្រើប្រាស់ប័ណ្ណប.ស.ស យ៉ាងហោចណាស់មានកសិករពីររូបដែលមានបទពិសោធន៍ប្រឈមនឹងការបាត់បង់សមាជិកគ្រួសារ ដោយសារការមិនយកចិត្តទុកដាក់នៅពេលដែលពួកគេទៅប្រើប្រាស់សេវាសុខភាពក្នុងអំឡុងពេលពីការរាតត្បាតនៃជំងឺកូវីដ-១៩។

“

*កូនស្រីខ្ញុំ គ្រប់ខែឆ្លងទន្លេ (សម្រាលកូន) ខ្ញុំបាននាំនាងទៅមណ្ឌលសុខភាពមួយ។ មណ្ឌលសុខភាពទុកនាងចោលមួយរសៀល ដោយប្រាប់ឱ្យខ្ញុំនិងគ្រួសាររងចាំ។ រហូតដល់យប់បន្តិច ទើបខាងមណ្ឌលសុខភាពប្រាប់ខ្ញុំថា ស្ថានភាពកូនស្រីខ្ញុំធ្ងន់ធ្ងរត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែក។ ទម្រាំរៀបចំឯកសារផ្ទេររួច កូនខ្ញុំឈឺពោះរងចាំរហូតដល់ងងឹត។ ពេលទៅដល់មន្ទីរពេទ្យបង្អែក បុគ្គលិកពេទ្យទីនោះ តម្រូវឱ្យកូនស្រីខ្ញុំនិងពួកយើងធ្វើតេស្តរកកូវីដ-១៩ ម្តងទៀត ដោយអះអាងថា តេស្តនៅមណ្ឌលសុខភាពមិនអាចយកជាការបានទេ។ ធ្វើតេស្តរួច ខាងមន្ទីរពេទ្យបង្អែកតម្រូវឱ្យរងចាំលទ្ធផលតេស្តសិន ហើយទុកកូនខ្ញុំចោលរហូតដល់ពាក់កណ្តាលយប់ បន្ទាប់មកគេប្រាប់ថា អត់មានពេទ្យទេ គេតម្រូវឱ្យបញ្ជូនកូនខ្ញុំទៅមន្ទីរពេទ្យបង្អែកខេត្តមួយទៀត។ ខ្ញុំបានរករឿង មិនព្រមយកកូនចេញពីពេទ្យ ព្រោះវាយប់ខ្លាំងណាស់ (ពាក់កណ្តាលអាធ្រាត្រ) ខ្លាចប៉ះពាល់ជីវិតកូនស្រីខ្ញុំ ពួកយើងរងចាំរហូតដល់ព្រឹកទើបមានពេទ្យ។ កូនខ្ញុំសំណាងល្អណាស់ដែលអាយុវែង។*

*សម្តីស្ត្រីកសិករម្នាក់ដែលរស់នៅក្នុងខេត្តព្រះវិហារ រៀបរាប់ពីបទពិសោធន៍របស់កូនស្រីគាត់*

”

បញ្ហាមួយចំនួនទៀតសម្រាប់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចជុំវិញការប្រើប្រាស់សេវាសុខភាពពេលគឺការចំណាយច្រើនជាងមុនទៅលើសេវានេះ ជាក់ស្តែងក្នុងករណីសមាជិកគ្រួសារមានជំងឺតម្រូវឱ្យសម្រាកព្យាបាល ឬពិគ្រោះយោបល់ ខាងមន្ទីរពេទ្យតម្រូវឱ្យពួកគេធ្វើតេស្តរកកូវីដ-១៩ ជាមុន ហើយតម្លៃនៃការធ្វើតេស្តមានភាពផ្សេងៗគ្នាទៅលើតាមតំបន់នីមួយៗ ហើយដែលតម្លៃអាចចាប់ពី ៥ម៉ឺនរៀល (១២.៥ដុល្លារ) ទៅ ១២ម៉ឺនរៀល (៣០ដុល្លារ) សម្រាប់ការធ្វើតេស្តម្តង។ ការចំណាយទៅលើការធ្វើតេស្តនេះ ជាបន្ទុកមួយទៀតសម្រាប់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច។

## ៤. ផលប៉ះពាល់លើជីវភាព និងការគាំទ្រនានារបស់រដ្ឋាភិបាលមកដល់កសិករខ្នាតតូច

### ៤.១. បញ្ហាធ្លាក់ចុះតម្លៃកសិផលរបស់កសិករនិងអ្នកផលិតស្បៀងអាហារ ខ្នាតតូច

“ *ស្វាយរបស់ខ្ញុំលក់បានមួយគីឡូ ២០០រៀល ប្រសិនបើ ឈ្មួញឱ្យថ្លៃបំផុតគឺ ៥០០រៀល ក្នុងមួយគីឡូក្រាម។*

*សម្ដីកសិករដែលមានចំការស្វាយ។* ”

“ *តម្លៃស្រូវចុះថោកជាងមុន ម្លិះក្រហមជាទូទៅមួយគីឡូតម្លៃ ២,០០០រៀល (០.៥ដុល្លារ) ប៉ុន្តែបច្ចុប្បន្ននេះ តម្លៃស្រូវម្លិះក្រហមធ្លាក់មកស្មើនឹងស្រូវចាប់ឆាយ (ស្រូវចម្រុះ) គឺក្នុងមួយគីឡូបានត្រឹម ១,១០០រៀល (០.២៧ដុល្លារ) ប៉ុណ្ណោះ។ ឈ្មួញកណ្ដាល បន្តកំណត់តម្លៃស្រូវ ហើយប្រសិនបើខ្ញុំមិនលក់ក្នុងតម្លៃដែលពួកគេដាក់ទេ គឺមានតែទុកស្រូវឱ្យខូចចោល។*

*សម្ដីកសិករខ្នាតតូច* ”

“ *ដោយសារតែឆ្នាំ ២០២០ មានទឹកជំនន់ស្រូវរបស់ខ្ញុំដែលបានធ្វើក្នុងផ្ទៃដី ១ហិចតា ៣០អា ត្រូវបានលិចលង់ទាំងស្រុង។ ឆ្នាំនេះ មានបញ្ហារាំងស្ងួតកាលពីដើមឆ្នាំ លុះដល់រដូវវស្សាទឹកបានជំនន់លិចស្រូវខ្ញុំម្ដងទៀង ខ្ញុំខាតទុនច្រើនណាស់។* ”

*សម្ដីកសិករម្នាក់ដែលរងគ្រោះដោយសារបម្រែបម្រួលអាកាសធាតុស្ទួនៗគ្នា ទាំងក្នុងឆ្នាំ២០២០ និង ឆ្នាំ ២០២១។*

“ *អ្នកស្រែដូចពួកយើងត្រូវចាំឈ្មួញប្រាប់ជាមុនសិនថាពេលណាស្រូវអាចច្រូតបាន។ ពួកគេ(ឈ្មួញ) មានចំណេះដឹងជាងពួកយើង។ ប្រសិនបើពួកយើងមិនធ្វើតាមគេទេ យើងអាចនឹងច្រូតស្រូវទុកចោលព្រោះគេ មិនទិញស្រូវពួកយើងទេ គេថាគ្មានស្ដង់ដា។* ”

*សម្ដីកសិករម្នាក់ចែករំលែកក្នុងកិច្ចប្រជុំពិគ្រោះយោបល់ពីលទ្ធផលបឋម*




*ទិន្នន័យបង្ហាញអំពីចំណូលរបស់កសិករ
និងអ្នកផលិតស្បៀងអាហារខ្នាតតូច*

កសិករចំនួន ៩២.២ភាគរយ មានចំណូលទាបជាងមុន ហើយបញ្ហាការធ្លាក់ចុះនៃចំណូលនេះ កើតឡើងចាប់តាំងពីមានការរាតត្បាតនៃជំងឺកូវីដ-១៩។ ទោះបីជាកសិករអាចប្រកបមុខរបរជាអ្នកធ្វើស្រែ ដាំដំណាំ និងចិញ្ចឹមសត្វ សម្រាប់ស្វែងរកចំណូលដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ក៏មុខរបរទាំងអស់នេះមិនសូវ បានជួយសម្រួលដល់ជីវភាព របស់ពួកគេដែរនៅក្នុងស្ថានភាពកូវីដ-១៩។

កសិករចំនួន ៩២.២ភាគរយ មានចំណូលទាបជាងមុន ហើយបញ្ហាការធ្លាក់ចុះនៃចំណូលនេះ គឺកើតឡើងចាប់តាំងពីមានការរាតត្បាតនៃជំងឺកូវីដ-១៩។ ទោះបីជាកសិករអាចប្រកបមុខរបរជាអ្នកធ្វើស្រែ ដាំដំណាំ និងចិញ្ចឹមសត្វសម្រាប់ស្វែងរកចំណូលដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ក៏មុខរបរទាំងអស់នេះមិនសូវបានជួយសម្រួលដល់ជីវភាពរបស់ពួកគេដែរនៅក្នុងស្ថានភាពកូវីដ-១៩។ កសិផលរបស់កសិករខ្នាតតូច មានការធ្លាក់ចុះជាងមុនជាក់ស្តែងដំណាំឪឡឹក ស្រូវ និងដំឡូងមីជាដើម ដោយសារវិបត្តិបណ្តាលពីបម្រែបម្រួលអាកាសធាតុ គឺភាពរាំងស្ងួត និងទឹកជំនន់។ ឈ្មួញបន្តមានអំណាចក្នុងការកំណត់តម្លៃកសិផល ដែលកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចធ្វើបាន។ ក្រៅពីពួកគេមានអំណាចផ្តាច់មុខក្នុងការកំណត់តម្លៃ ឈ្មួញក៏មានអំណាចក្នុងការកំណត់ពេលវេលាក្នុងការប្រមូលកសិផល ជាអាទិ៍មុនសម្រេចចិត្តប្រមូលផលស្រូវកសិករក្នុងតំបន់មួយចំនួនត្រូវជាមួយឈ្មួញ ជាមុនថាតើស្រូវដែលពួកគាត់ធ្វើនោះទុំអាចប្រមូលផលបានឬទេ។

តម្លៃកសិផល និងសត្វពាហនៈ បន្តជួបប្រទះបញ្ហាការធ្លាក់ចុះតម្លៃ ឬលក់មិនចេញ បើធៀបទៅនឹងតម្លៃទំនិញនៅលើទីផ្សារដែលបន្តឡើងខ្ពស់។ តម្លៃស្រូវបន្តថេរក្នុងមួយចំនួន និងមានការធ្លាក់ចុះតម្លៃស្រូវខ្លាំងក្នុងតំបន់មួយចំនួនទៀត។ ក្នុងតំបន់ដែលស្រូវធ្លាក់ថ្លៃខ្លាំងដូចជាខេត្តបន្ទាយមានជ័យ តម្លៃស្រូវលក់ចេញ ដូចជាស្រូវសែនក្រអូបដែលធ្លាប់លក់បានក្នុងតម្លៃ ៨០ម៉ឺនរៀលក្នុង ១តោន (២០០ដុល្លារ) ប៉ុន្តែឆ្នាំ ២០២០ និងឆ្នាំ ២០២១ ស្រូវ ប្រភេទនេះដដែលលក់បានត្រឹម ៦០ម៉ឺនរៀលក្នុង ១តោន (១៥០ដុល្លារ) ស្រូវស្រាលដូចជា ស្រូវអ៊ីអ៊ែរធ្លាក់តម្លៃពី ៨៣០រៀល (០.២១ដុល្លារ) ក្នុង ១គីឡូក្រាម ក្នុងឆ្នាំ ២០២០ មក

ត្រឹម ៧២០រៀល (០.១៨ដុល្លារ) ក្នុង ១គីឡូក្រាម។ ហើយតម្លៃនេះដែរ កសិករមួយចំនួនថា បើពួកគាត់មិនលក់ក្នុងតម្លៃនេះមានតែទុកស្រូវចោល ដូចនេះ កសិករភាគច្រើនត្រូវបង្ខំចិត្តលក់។ ក្នុងតំបន់ខ្លះ តម្លៃស្រូវត្រូវបានទម្លាក់ពីសំណាក់ឈ្មួលទិញស្រូវ ឬឈ្មួញកណ្ដាល ដោយសារមិនមានឈ្មួញចូលមកទិញដល់កន្លែងច្រើនដូចមុន។ ស្រូវពូជមានតម្លៃខ្ពស់ដដែល ដោយក្នុង ១០០គីឡូ មានតម្លៃ ១២ម៉ឺនរៀល (៣០ដុល្លារ)។ កសិករមួយចំនួនត្រូវសម្រេចពន្លឿនការច្រូតកាត់ ឬក៏ច្រូតកាត់ទៅតាមការកំណត់ពីឈ្មួញដើម្បីបញ្ចៀសការទម្លាក់តម្លៃខ្លាំង ឬការទុកស្រូវចោលដោយគ្មានអ្នកទិញ។

បន្លែ (ដូចជាម្ទេស ត្រប់ស្រួយ ឆៃថាវ និងត្រប់វែង) និងផ្លែឈើមានតម្លៃធ្លាក់ចុះខ្លាំងផ្ទុយពីបន្លែនៅលើទីផ្សារដែលនាំចូលថ្លៃជាងមុន ជាហេតុកសិករមួយចំនួនសម្រេចចិត្តភ្ជួរបន្លែរបស់ពួកគាត់ចោល។ តម្លៃម្ទេស ទទួលរង ផលប៉ះពាល់ខ្លាំង។ ក្រៅពីដំណាំម្ទេស និងកសិផលមួយចំនួនទៀត ពិសេសដំណាំកសិកម្មសម្រាប់ការនាំចេញ ព្រមទាំងផ្លែឈើមួយចំនួនទៀតជួបប្រទះនឹងការធ្លាក់ចុះតម្លៃយ៉ាងគំហុគ ក្នុងនោះមានផ្លែមៀនប៉ៃលិន ឬតាង៉ែន និងផ្លែស្វាយជាដើម។ កសិករមួយចំនួននៅក្នុងខេត្តឧត្តរមានជ័យថា តម្លៃស្វាយធ្លាក់ចុះយ៉ាងខ្លាំង សូម្បីតែលក់ក្នុងតម្លៃ ១០០រៀលក្នុង ១គីឡូក្រាម ក៏គ្មាននរណាបញ្ជាទិញដែរ។ ដំឡូងក៏ស្រដៀងគ្នាដែរ នាពេលប្រមូលផលដើមឆ្នាំ តម្លៃដំឡូងគឺប្រមាណជាង ២០០០រៀល (០.៥ដុល្លារ) ប៉ុន្តែបច្ចុប្បន្នសូម្បីតែតម្លៃ ១០០ រៀល (០.២៥ដុល្លារ) ក៏គ្មានអ្នកទិញដែរ។ ដោយឡែក តម្លៃធាតុចូលកសិកម្មបន្តកើនឡើង ជាក់ស្តែង ថ្នាំពុលនិងជីគីមីកសិកម្មបន្តឡើងថ្លៃខ្ពស់ ជាងមុន ជាអាទិ៍ជីបំប៉នស្រូវ អ៊ុយរ៉េ ពីមុនមានតម្លៃ ៨ម៉ឺនក្នុង (២០ដុល្លារ) ក្នុង ១បាវ ឬស្មើនឹង ៥០គីឡូក្រាមនៅក្នុងឆ្នាំ ២០២០ ហើយបច្ចុប្បន្នតម្លៃជី ១បាវ ឬស្មើនឹង ៥០គីឡូក្រាម បានឡើងដល់ ១២ម៉ឺន (៣០ដុល្លារ) ទៅដល់ ១៩ម៉ឺនរៀល (៤៧.៥ដុល្លារ) ក្នុង ១បាវ ឬស្មើនឹង ៥០គីឡូក្រាម ក្នុងឆ្នាំ ២០២១។ រីឯតម្លៃម៉ាស៊ូតក៏មានការកើនឡើងយ៉ាងគំហុកផងដែរ គឺពីចន្លោះ ៧ម៉ឺនរៀល ទៅ ៩៣០០០រៀល សម្រាប់ម៉ាស៊ូត ៣០លីត្រក្នុងឆ្នាំ ២០២០ ហើយមានតម្លៃ ១០៥០០០រៀល ទៅ ១២ម៉ឺនរៀល សម្រាប់ម៉ាស៊ូត ៣០លីត្រក្នុងឆ្នាំ ២០២១។

កសិករជាច្រើននាក់ដែលចិញ្ចឹមគោ បានរៀបរាប់ដូចគ្នាពីបញ្ហាប្រឈមរបស់ពួកគាត់ទៅនឹងការកើតឡើងនូវជំងឺរាតត្បាតសត្វគោ ឬដែលត្រូវបានស្គាល់ថាជាជំងឺដុំពក ដែលវាបានបណ្ដាលឱ្យគោរបស់ពួកគាត់ងាប់អស់ជាច្រើនក្បាល។ ជំងឺដុំពក ត្រូវបានរាយការណ៍ថា វាបន្ថែមបន្ទុកមួយទៀតសម្រាប់កសិករខ្នាតតូច ពិសេសសម្រាប់កសិករមួយចំនួនដែល ចិញ្ចឹមគោជាមុខរបរបន្ថែម។ ក្រៅពីជំងឺដុំពកដែលកើតឡើងមកលើសត្វគោ បញ្ហាជំងឺអាសន្នរោគកើតឡើងមកលើសត្វមាន់ ក៏ជាបញ្ហាដ៏ធំមួយផងដែរដែលបានបណ្ដាលឱ្យគ្រួសារកសិករមួយចំនួនស្ទើរតែបាត់បង់ជីវភាពទាំងស្រុង ពិសេសនៅពេលដែលមាន់របស់ពួកគាត់បានឆ្លងជំងឺនេះ និងស្លាប់ភ្លាមៗ។ បញ្ហារាំងស្ងួត អាកាសធាតុក្តៅ ឬការកើនឡើងនៃកម្ដៅ និងបញ្ហាបិរបទខ្យល់ ទឹក និងការប្រើប្រាស់សារធាតុពុល និងគីមីពីអ្នកជុំវិញខ្លួនមួយចំនួនបណ្ដាលឱ្យប៉ះពាល់ដល់សត្វពាហនៈនិងឈឺងាប់ជាបន្តបន្ទាប់។

ខណៈពេលដែលកសិករភាគច្រើន មិនទទួលបានការគាំទ្រពីកម្មវិធីជួយប្រមូលទិញផលិតផល




*ទិន្នន័យនេះបង្ហាញអំពីការទទួលបានការគាំទ្រពីកម្មវិធីឥណទានគាំទ្រដល់សហគ្រាសកសិកម្មខ្នាតតូច និងមធ្យមតាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម*

កសិកម្មក្នុង តម្លៃសមរម្យពីសំណាក់រដ្ឋាភិបាល មានភាគតិចណាស់ដែលកសិករបានទទួលការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ មន្ទីរកសិកម្ម មន្ទីរពាក់ព័ន្ធនានា ឬពីសំណាក់អាជ្ញាធរមូលដ្ឋាន ដូចជា ការរកទីផ្សារ ឬភ្ជាប់ពួកគាត់ជាមួយទីផ្សារក្នុងស្រុកមួយចំនួន។ ចំពោះការជួយរកទីផ្សារ ឬភ្ជាប់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចជាមួយទីផ្សារ កសិករយ៉ាងច្រើនលើសលុបរហូតដល់ទៅ ៩៦ភាគរយ មិនបានទទួលការជួយសម្របសម្រួលទេ។

កសិករចំនួន ១០០នាក់ ឬស្មើនឹង ៩២.២ភាគរយ មិនធ្លាប់ទទួលបានការគាំទ្រពីកម្មវិធីឥណទានគាំទ្រដល់សហគ្រាសកសិកម្មខ្នាតតូច និងមធ្យមដែលមានទឹកប្រាក់ជាមួយទឹកប្រាក ៥០លានដុល្លារ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ជាមួយអាត្រាការប្រាក់ទាបនោះទេ។

កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចច្រើនលើសលុប ឬស្មើនឹង ៩០ភាគរយ មិនបានទទួលការ គាំទ្រជាគ្រាប់ពូជ (ស្រូវ ដំណាំ ឬបន្លែ) បើធៀបទៅនឹងកសិករត្រឹមតែ ៩ភាគរយ ដែលបានទទួលការគាំទ្រ។ កសិករចំនួន ៩៧ភាគរយ មិនបានទទួលការគាំទ្រពូជសត្វ ដោយឡែកមានតែកសិករចំនួន២ភាគរយប៉ុណ្ណោះ ដែលបានទទួលផលប្រយោជន៍ពីការគាំទ្រនេះ។ កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចស្ទើរតែទាំងអស់ ឬ ៩៦ភាគរយ មិនបានទទួលជំនួយផ្នែកបច្ចេកទេសកសិកម្មពីអាជ្ញាធរពាក់ព័ន្ធ បើធៀបទៅនឹងកសិករចំនួនតែ ៣ភាគរយប៉ុណ្ណោះដែលធ្លាប់ទទួលការគាំទ្រ។ កសិករតែ ២ភាគរយ មានបទពិសោធទទួលបានការគាំទ្រនេះ។

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៧៣ភាគរយ មិនបានឃើញ ឬទទួលបានផលប្រយោជន៍ពីការកសាង ឬការស្តារប្រព័ន្ធធារាសាស្ត្រក្នុងភូមិស្រុករបស់ពួកគាត់ នៅពេលដែលកសិករចំនួន ២៤ភាគរយ បានឃើញពីការកសាងទាំងនេះ ដោយឡែកពួកគេមិនទាន់ទទួលបានផលពីគម្រោង

## ៤.២. បញ្ហាកង្វះស្បៀងអាហារ និងការគាំទ្រដល់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៦២នាក់ ឬស្មើនឹង ៥៩.៦ភាគរយ មិនមានអាហារ ទទួលទានគ្រប់គ្រាន់ បើធៀបទៅនឹងកសិករចំនួន ៤១នាក់ ឬស្មើនឹង ៣៩.៤ភាគរយ មានអាហារទទួលទានគ្រប់គ្រាន់។ ក្នុងចំណោមកសិករដែលមានអាហារទទួលទានគ្រប់គ្រាន់ កសិករខ្នាតតូចចំនួន ៦៥.៩ភាគរយ មានអាហារសម្រាប់ផ្គត់ផ្គង់ គ្រួសារលើសពី ៦ខែ ផ្ទុយពីកសិករចំនួន ១៩.៥ភាគរយ មានអាហារសម្រាប់ផ្គត់ផ្គង់គ្រួសារចន្លោះពី ៣ខែ-៦ខែ រីឯ កសិករចំនួន ៤.៩ភាគរយផ្សេងទៀតក្នុងចំណោមកសិករដែលមានអាហារសម្រាប់ទទួលទាន ពួកគាត់ថា អាចផ្គត់ផ្គង់គ្រួសារមានអាហារទទួលទានតិចជាង ១ខែប៉ុណ្ណោះ។




*ទិន្នន័យបង្ហាញអំពីការទទួលទានអាហាររបស់កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូច*

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៤០.៤ភាគរយ ចំណាយទៅលើអាហារជាមធ្យមចន្លោះពី ១១,០០០រៀល-២០,០០០រៀល (២.៧ដុល្លារ-៥ដុល្លារ) មួយគ្រួសារក្នុងមួយថ្ងៃ កសិករខ្នាតតូចចំនួន ១៣.៥ភាគរយ ចំណាយច្រើនជាងពាក់កណ្ដាលទៅលើអាហារ ឬចំណាយចន្លោះពី ៥,១០០រៀល-១០០,០០០រៀល (៧.៧ដុល្លារ-២៥ដុល្លារ) មួយគ្រួសារក្នុងមួយថ្ងៃ។ កសិករចំនួន ៨.៧ភាគរយ ចំណាយចន្លោះពី ៣១,០០០រៀល-៤០,០០០រៀល (៧.៧ដុល្លារ-១០ដុល្លារ) ស្រដៀងគ្នានេះ កសិករខ្នាតតូចចំនួន ២០.២ភាគរយ ចំណាយចន្លោះពី ២១,០០០រៀល-៣០,០០០រៀល (៥.២ដុល្លារ-៧.៥ដុល្លារ) ក្នុងមួយថ្ងៃ។ កសិករជិត ១០ភាគរយ ដែលចំណាយតិចតួចទៅលើអាហាររបស់ពួកគេគិតជាមធ្យមក្នុងមួយថ្ងៃ ដោយចំណាយច្រើនជាង ៥០០០រៀល (ឬច្រើនជាង ១.២ដុល្លារ) ក្នុងមួយថ្ងៃ។




*ទិន្នន័យបង្ហាញអំពីការចំណាយទៅលើអាហារប្រចាំថ្ងៃ របស់កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូច*

កសិករខ្នាតតូចចំនួន ៤២.៣ភាគរយ បានចំណាយទៅលើអាហារច្រើនជាងមុន បើធៀបទៅនឹង ២៨.៨ភាគរយ ចំណាយតិចជាងមុននៅពេលដែលកសិករចំនួន ២៨.៨ភាគរយ ការចំណាយទៅលើអាហារប្រចាំថ្ងៃមានភាពធម្មតា។ ក្នុងចំណោមកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចដែលបានចំណាយច្រើនជាងមុនទៅលើអាហារប្រចាំថ្ងៃកសិករចំនួន ៣៥.៦ភាគរយ ចំណាយច្រើនជាងមុន ១០,០០០រៀល (២.៥ដុល្លារ) ក្នុងមួយថ្ងៃ។ កសិករខ្នាតតូចចំនួន ២៦.៧ភាគរយ ចំណាយច្រើនជាងមុនចន្លោះពី ៨,១០០រៀល-១០,០០០រៀល (២.២៥ដុល្លារ-២.៥ដុល្លារ) ក្នុងមួយថ្ងៃ ហើយកសិករ ២២.២ភាគរយ ចំណាយទៅលើអាហារច្រើនជាងមុនចន្លោះពី ៥,១០០រៀល-៨,០០០រៀល (១.២៧ដុល្លារ-២ដុល្លារ)



*រូបភាពបង្ហាញពីការលក់ដូរបន្លែនៅតាមដងផ្លូវ ក្នុងអំឡុងបិទខ្ទប់ក្នុងរាជធានីភ្នំពេញ*

ក្នុងមួយថ្ងៃ។ ដោយឡែកកសិករខ្នាតតូចចំនួន ១៣.៣ភាគរយ ចំណាយចន្លោះពី ២១,០០រៀល-៥,០០០រៀល (០.៥២ដុល្លារ-១.០៥ដុល្លារ) ក្នុងមួយថ្ងៃ។ កសិករមានត្រឹមតែ ២.២ភាគរយប៉ុណ្ណោះដែលចំណាយចន្លោះពី តិចជាងឬស្មើនឹង ២,០០០រៀល (តិចជាងឬស្មើនឹង ០.៥ដុល្លារ) ក្នុងមួយថ្ងៃ។

ចំពោះកសិករដែលចំណាយតិចជាងមុនទៅលើអាហារ កសិករចំនួន ២៧.៦ភាគរយ ចំណាយតិចជាងមុនចន្លោះពី ២,១០០រៀល-៥,០០០រៀល (០.៥២ដុល្លារ-១.២៥ដុល្លារ) មួយគ្រួសារក្នុងមួយថ្ងៃ។ កសិករចំនួន ២៤.១ ចំណាយតិចជាងមុនចន្លោះពី ៨,១០០រៀល-១០,០០០រៀល (២.២៥ដុល្លារ-២.៥ដុល្លារ) ផ្ទុយពីកសិករដែលចំណាយតិចជាងឬស្មើនឹង ២,០០០រៀល (០.៥ដុល្លារ) ដែលមានចំនួន ១០.៣ភាគរយ។ ផងដែរនោះ កសិករចំនួន ២៤.១ភាគរយផ្សេងទៀត ដែលចំណាយតិចជាមុន តិចជាង ១០,០០០រៀល (តិចជាង ២.៥ដុល្លារ) ដែលការចំណាយនេះប្រហាក់ប្រហែលទៅនឹងកសិករមានចំនួន ១៣.៨ភាគរយ ដែលចំណាយមានចន្លោះពី ៥,១០០រៀល-៨,០០០រៀល (១.២៧ដុល្លារ-២ដុល្លារ) ក្នុងមួយថ្ងៃ។

តាមរយៈការអង្កេតរបស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច សមាជិកគ្រួសារក្នុងសហគមន៍ឬភូមិរបស់ពួកគាត់ដែលកំពុងប្រឈមនឹងបញ្ហាកង្វះស្បៀងអាហារមានចំនួនផ្សេងៗគ្នា។ ក្នុងចំណោមនោះ ១៣.៥ភាគរយ នៃកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចដែលចូលរួមអង្កេតថា គ្រួសារក្នុងសហគមន៍ឬក្នុងភូមិ មានចំនួនចន្លោះពី ២១គ្រួសារ ទៅ ៣០គ្រួសារ កំពុងប្រឈមនឹងកង្វះស្បៀងអាហារ។ កសិករដែលផ្តល់បទសម្ភាសន៍ចំនួន ៤១.៣ភាគរយថា ថាគ្រួសារតិចជាង ៥០គ្រួសារ កំពុងប្រឈមនឹងកង្វះស្បៀងអាហារ បើធៀបទៅនឹងសិករចំនួន ៩.៦ភាគរយ គ្រួសារក្នុងភូមិដែលកំពុងប្រឈមនឹងកង្វះស្បៀងអាហារមានចន្លោះពី ៣១គ្រួសារ ទៅ ៤០គ្រួសារ។

អ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៣៧នាក់ ឬស្មើនឹង ៣៥.៦ភាគរយ គ្មានទឹកសម្រាប់ទទួលទាន មិនដូចកសិករចំនួន ៦៧នាក់ ឬស្មើនឹង ៦៤.៤ភាគរយ មានទឹកសម្រាប់ទទួលទាន។ កសិករ ៦៧.៣ភាគរយ មិនមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពដំណាំ ហើយមានតែ ២៨.៨ភាគរយប៉ុណ្ណោះដែលមានទឹកសម្រាប់ស្រោចស្រពដំណាំ។ ទឹកសម្រាប់ប្រើប្រាស់ទូទៅក្នុងផ្ទះ ៣៥.៦ភាគរយ មិនមានទឹកសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ នៅពេលដែល ៦៣.៥ មានទឹកប្រើប្រាស់គ្រប់គ្រាន់ក្នុងគ្រួសារ។

ទឹកភ្លៀងគឺនៅតែជាប្រភពដ៏សំខាន់សម្រាប់កសិករធ្វើស្រែ និងស្រោចស្រពដំណាំ។ ក្រៅពីការពឹងផ្អែកទៅលើទឹកភ្លៀង អណ្តូងជាលក្ខណៈគ្រួសារ ឬធនធានទឹករួមក្នុងភូមិ (ដូចជា អណ្តូងទឹករួម ស្រះ អូរ ស្ទឹង ទន្លេ បឹងបួរ) ក៏ជាប្រភពទឹកមួយទៀតដ៏សំខាន់សម្រាប់ការដាំដុះដំណាំជាលក្ខណៈគ្រួសារ។ កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច ពឹងផ្អែកទៅលើការទិញទឹកសុទ្ធ ទឹកភ្លៀង ទឹកអណ្តូង និងទឹកដែលផ្គត់ផ្គង់ដោយរដ្ឋករទឹកកម្ពុជាសម្រាប់ទទួលទាន និងប្រើប្រាស់ទូទៅក្នុងគ្រួសារប្រចាំថ្ងៃ។ ក៏ប៉ុន្តែក្នុងតំបន់នៃខេត្តមួយចំនួន ប្រឡាយរួម ឬទឹកស្ទឹងរួមត្រូវបានធ្វើអាជីវកម្មដោយក្រុមហ៊ុន ឬបុគ្គលមានធនធានឯកជនក្នុងស្រុក ហើយពួកគេមានសិទ្ធិទៅលើការកំណត់តម្លៃទឹកដែលកសិករនិងអ្នកផលិត




*ទិន្នន័យបង្ហាញអំពីបទពិសោធន៍ នៃការទទួលទាន និងការប្រើប្រាស់ទឹករបស់កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូច*

ស្បៀងអាហារប្រើប្រាស់។ ជាក់ស្តែង កសិករខ្នាតតូចក្នុងខេត្តចំនួនពីរ លើកឡើងពីបញ្ហាការចំណាយទៅលើទឹកសម្រាប់ក្នុងការបង្កបង្កើនផលដែលមានតម្លៃចន្លោះពី ២៥ម៉ឺនរៀល (៦២.៥ដុល្លារ) ទៅដល់ ៣៥ម៉ឺនរៀល (៨៧.៥ដុល្លារ) ក្នុងមួយហិចតាទៅកាន់អ្នកផ្គត់ផ្គង់ទឹកឯកជនដែលបានទទួលការអនុញ្ញាតលក់ទឹកប្រឡាយឱ្យកសិករ។ ចំពោះតម្លៃទឹកនេះទៀតសោតមិនបានបញ្ចូលការចំណាយរបស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចទៅលើការចំណាយម៉ាស៊ូតដើម្បីបូមទឹកដាក់ស្រែរបស់ពួកគាត់។

កសិករចំណាយផ្សេងៗគ្នា ទៅលើការប្រើប្រាស់ទឹកជាមធ្យមក្នុងមួយខែ។ កសិករមានចំនួន ២៧.៧ភាគរយ ចំណាយច្រើនជាងមុន រហូតដល់ ១០,០០០រៀល (២.៥ដុល្លារ) ក្នុងមួយខែ។ កសិករចំនួន ២២.៨ភាគរយ ចំណាយតិចជាង ៥០,០០០រៀល (១២.៥ដុល្លារ) ក្នុងមួយខែ បើធៀបទៅនឹងកសិករចំនួន ៧.៩ភាគរយ ចំណាយតិចជាង ចន្លោះពី ៤១,០០០រៀល-៥០,០០០រៀល (១០.២៥ដុល្លារ-១២.៥ដុល្លារ)។ កសិករ ១៣.៩ភាគរយ ចំណាយទៅលើទឹកជាមធ្យមក្នុងមួយខែចន្លោះពី ៣១,០០០រៀល-៤០,០០០រៀល (៧.៧៥ដុល្លារ-១០ដុល្លារ) ហើយកសិករ ១៨.៨ភាគរយ ចំណាយទៅលើទឹកជាមធ្យមចន្លោះពី ១១,០០០រៀល-២០,០០០រៀល (២.៧៥ដុល្លារ-៥ដុល្លារ)។

កសិករចំណាយផ្សេងៗគ្នា ទៅលើការប្រើប្រាស់ទឹកជាមធ្យមក្នុងមួយខែ។ កសិករមានចំនួន ២៧.៧ភាគរយ ចំណាយច្រើនជាងមុន រហូតដល់ ១០,០០០រៀល (២.៥ដុល្លារ) ក្នុងមួយខែ។ កសិករចំនួន ២២.៨ភាគរយ ចំណាយតិចជាង ៥០,០០០រៀល (១២.៥ដុល្លារ) ក្នុងមួយខែ បើធៀបទៅនឹង

កសិករចំនួន ៧.៩ភាគរយ ចំណាយតិចជាង ចន្លោះពី ៤១,០០០រៀល-៥០,០០០រៀល (១០.២៥ដុល្លារ-១២.៥ដុល្លារ)។ កសិករ ១៣.៩ភាគរយ ចំណាយទៅលើទឹកជាមធ្យមក្នុងមួយខែចន្លោះពី ៣១,០០០រៀល-៤០,០០០រៀល (៧.៧៥ដុល្លារ-១០ដុល្លារ) ហើយកសិករ ១៨.៨ភាគរយ ចំណាយទៅលើទឹកជាមធ្យម ចន្លោះពី ១១,០០០រៀល-២០,០០០រៀល (២.៧៥ដុល្លារ-៥ដុល្លារ)។

បញ្ហាមួយចំនួនដែលបណ្ដាលឱ្យកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចជួបប្រទះ ទៅនឹងកង្វះស្បៀង មានដូចជា ការបិទផ្អាកដំណើរការការងារភ្លាមៗរបស់សមាជិកគ្រួសារដែលជាអ្នករកចំណូលចំបង សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ពិសេសគ្រួសារកសិករដែលពឹងផ្អែកទៅលើប្រាក់បញ្ញើររបស់កូនដែលធ្វើការក្នុងរោងចក្រ ឬចំណាកស្រុក។ ផងដែរ មានបញ្ហាធ្លាក់ចុះនូវតម្លៃកសិផលពីការធ្វើស្រែចំការដែល វាមិនមានសមតុល្យទៅ នឹងការចំណាយទៅលើធាតុចូលកសិកម្ម និងថ្លៃឈ្នួលកម្លាំងពលកម្ម ប្រេងសាំង ឬតម្លៃម៉ាស៊ីនច្រូតកាត់។ គ្រោះរាំងស្ងួត និងទឹកជំនន់បានបំផ្លិចបំផ្លាញស្រូវនិងកសិផល ក្នុងតំបន់មួយចំនួនយ៉ាងធ្ងន់ធ្ងរ ហើយដែលផលប៉ះពាល់ពួកគាត់ជួបប្រទះគឺមានរយៈពេលពីរឆ្នាំជាប់ៗគ្នា។ បញ្ហាគ្រោះធម្មជាតិដែលបណ្ដាលពីបម្រែបម្រួលអាកាសធាតុបានបន្ថែមបន្ទុក និងផលប៉ះពាល់មួយកម្រិតទៀតមកលើកសិករ។ វិបត្តិបណ្ដាលពីការរាតត្បាតនៃជំងឺកូវីដ-១៩ បានធ្វើឱ្យជីវភាពពួក ដុនដាបជាងមុន ស្របពេលដែលពួកគាត់ មិនមានដីធ្លីសម្រាប់ធ្វើស្រែចំការដោយសារធនធានទាំងនោះ ត្រូវបានទន្ទ្រាន ឬដកហូតយកពីសំណាក់ក្រុមហ៊ុន ឬពីបុគ្គលមានអំណាចនៅក្នុងតំបន់។ បន្ថែមពីនេះ ពួកគាត់បន្តទទួលបានដីការកោះពីតុលាការជាញឹកញាប់ ដែលប៉ះពាល់ដល់ការរកចំណូលប្រចាំថ្ងៃ។

ការឡើងថ្លៃអាហារ និងទំនិញនៅលើទីផ្សារ ទាំងអំឡុងពេលបិទខ្ទប់ និងក្រោយពេលបិទខ្ទប់ ជាឧបសគ្គដ៏ធំមួយ ធ្វើឱ្យកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចមួយចំនួនមិនមានស្បៀងអាហារគ្រប់គ្រង។ មួយវិញទៀតផងដែរ ការវិលត្រឡប់របស់កូនឬសមាជិកគ្រួសារដែលជាអ្នករកចំណូលសំខាន់ក្នុងគ្រួសារពីប្រទេសជិតខាង ដូចជាប្រទេសថៃ ដោយសារការបិទខ្ទប់ និងការបញ្ជូនជនបរទេសវិលត្រឡប់មកវិញ បានផ្ដល់ផលលំបាកមួយទៀតចំពោះការផ្គត់ផ្គង់ស្បៀងអាហារក្នុងគ្រួសារ ជាពិសេសសម្រាប់គ្រួសារដែលមានសមាជិកច្រើន។

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៧៥ភាគរយ មិនទទួលបានការគាំទ្រពីកម្មវិធីផ្ដល់សាច់ប្រាក់ជូនគ្រួសារក្រីក្រ និងជនងាយរងគ្រោះក្នុងវិបត្តិនៃជំងឺកូវីដ-១៩ បើធៀបទៅនឹងកសិករមានត្រឹមចំនួន ២៤ភាគរយប៉ុណ្ណោះ ដែលទទួលបានការគាំទ្រពីកម្មវិធីនេះ។ ក្នុងចំណោមកសិករដែលមិនទទួលបានផលប្រយោជន៍ពីកម្មវិធីគាំទ្រនេះ មួយចំនួនមិនទទួលបានព័ត៌មានជុំវិញការធ្វើ ឬប្ដូរប័ណ្ណក្រីក្រជាថ្មី នៅពេលដែលកសិករមួយចំនួនទៀត មិនបានជាប់លក្ខខណ្ឌក្នុងការទទួលបានប័ណ្ណក្រីក្រ បើទោះបីជាស្ថានភាពគ្រួសាររបស់ពួកគាត់ក្រីក្រក៏ដោយ។ កសិករខ្នាតតូចមួយចំនួនទៀត មានបទពិសោធន៍មិនទទួលបានការគាំទ្រដោយសារប័ណ្ណពួកគាត់ មិនជាប់ក្នុងកម្រិតដែលអាចទទួលបានការគាំទ្រ។ ខ្លះទៀតថាពេលពួកគាត់ទៅចុះឈ្មោះធ្វើប័ណ្ណក្រីក្រ អាជ្ញាធរតែងតែប្រាប់ពួកគាត់ថាអស់ពាក្យស្នើសុំ។ កសិករដែល

ជាសកម្មជនដីធ្លី ឬកសិករមួយចំនួនដែលត្រូវបានចោទប្រកាន់ថាមានពាក់ព័ន្ធជាមួយនិន្នាការនយោបាយ ឬជាសមាជិកគណបក្សប្រឆាំង មានបទពិសោធន៍ទទួលរងការរើសអើងពីសំណាក់អាជ្ញាធរមូលដ្ឋាន ពេលពួកគាត់ព្យាយាមស្វែងរកការគាំទ្រជំនួយនាអំឡុងពេលបិទខ្ទប់។

ទាំងកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច ដែលមានអាហារទទួលទានគ្រប់គ្រាន់ និងមិនគ្រប់គ្រាន់ ពួកគាត់ប្រើប្រាស់វិធីនានាដែលមានលក្ខណៈស្រដៀងគ្នាក្នុងការដោះស្រាយបញ្ហាកង្វះស្បៀងអាហារក្នុងគ្រួសារ។ កសិករមួយចំនួនបានជ្រើសរើសបណ្តាក់ស្បៀងអាហារ (ជំពាក់ប្រាក់ទៅលើថ្លៃអាហារ) ម្តងម្កាលពីអ្នកភូមិផ្សេងទៀត ឬដោយការសន្សំសំចៃ និងកាត់បន្ថយការចំណាយទៅលើរបប និងបរិមានអាហារ (ដូចជាដោយការទទួលទានស៊ុត(ពងទា ពងមាន់) ទឹកត្រី ឬបន្លែដែលពួកគាត់ដាំបាន ឬរកបាននៅជុំវិញផ្ទះ ឬស្រែជាដើម) ឬការកាត់បន្ថយអាហារពីមួយថ្ងៃបីពេលមកត្រឹមពីរពេលជំនួសវិញ។ កសិករខ្លះទៀតបាន កាត់បន្ថយការចំណាយពុំសូវជាចាំបាច់ប្រចាំថ្ងៃមួយចំនួន។ កសិករមួយចំនួនបាន ដើររកត្រីក្តាម ខ្យង ឬចូលព្រៃរកផ្សិត បន្លែ ឬដាំដំណាំចម្រុះបន្ថែមជាលក្ខណៈគ្រួសារ ដើម្បីទទួលទាន។ កសិករខ្នាតតូចខ្លះទៀត បានខ្ចីលុយអ្នកជិតខាង អ្នកចងការប្រាក់ឯកជន ឬខ្ចីប្រាក់ពីក្រុមសន្សំ ស្ត្រីនៅក្នុងភូមិ ឬលក់ទ្រព្យកេរ្តិ៍ (ទ្រព្យសម្បត្តិ) ឬលក់សត្វពាហនៈដែលចិញ្ចឹមបាន ដើម្បីដោះស្រាយបញ្ហាកង្វះស្បៀងមួយគ្រា កសិករមួយចំនួនបន្តរកការងារផ្សេងៗធ្វើដោយរួមទាំងការស៊ីឈ្នួលប្រចាំថ្ងៃ លក់កម្លាំងពលកម្មដូចជា ស៊ីឈ្នួលបេះម្ទេស ដាំឱឡឹក ដកដំឡូង ឬច្រូតស្រូវ ជួយវេចខ្ចប់សង្វាក់ ណែមត្រី កោសដូងឱ្យគេ ជាដើម។ សម្រាប់កសិករមួយចំនួនទៀតដំណោះស្រាយគឺពឹងផ្អែកទៅលើការរកចំណូលពីការលក់កម្លាំងពលកម្មតែមួយមុខដោយសារពួកគេមិនមានដីធ្លីធ្វើកសិកម្ម ហើយកំពុងបន្តប្រឈមនឹងដីការកោះហៅពីតុលាការជាញឹកញាប់។



*រូបភាពបង្ហាញពីការហាលស្រូវ នៅខេត្តបាត់ដំបង*

## ៥. បញ្ហារអន្ទាក់ និងវដ្តនៃបំណុលរបស់កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូច

កសិករចំនួន ៥១.១ភាគរយ ធ្លាប់មានការលំបាកក្នុងការសងបំណុលត្រឡប់ទៅកាន់ស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬធនាគារពាណិជ្ជក្នុងអំឡុងពេលនៃវិបត្តិពីការរាតត្បាតនៃជំងឺកូវីដ-១៩ បើយោងទៅតាមរបាយការណ៍ឆ្នាំ ២០២០។ បើទោះបីជា រដ្ឋាភិបាលបង្ហាញការតាំងចិត្តក្នុងការដោះស្រាយបញ្ហាបំណុលរបស់ប្រជាពលរដ្ឋពិសេសក្នុងឆ្នាំ ២០២១ក៏ដោយ ក៏អត្រាភាគរយនៃកសិករខ្នាតតូចដែលមានការលំបាកក្នុងការសងបំណុលកសិករត្រឡប់ទៅកាន់ធនាគារពាណិជ្ជ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ មានភាគរយលើសពីឆ្នាំមុន ឬមានចំនួនត្រឹមតែ ២.៧ភាគរយនៃកសិករខ្នាតតូចដែលមានការពិបាកក្នុងការសងបំណុលត្រឡប់ក្នុងឆ្នាំ ២០២០ បើធៀបទៅនឹង កសិករមានរហូតដល់ទៅពាក់កណ្តាលក្នុងឆ្នាំ ២០២១ ឬស្មើនឹង ៥៣.៨ភាគរយដែលមានការលំបាកក្នុងការសងបំណុលត្រឡប់។




*តារាងនេះបង្ហាញពីការប្រៀបធៀបនៃបទពិសោធន៍លំបាករបស់កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចក្នុងការសងបំណុលក្នុងឆ្នាំ ២០២០ និងឆ្នាំ ២០២១*

កសិករចំនួន ២៥ភាគរយ នៃអ្នកដែលធ្លាប់មានបញ្ហាលំបាកក្នុងការសងបំណុល បានចរចាជាមួយធនាគារ ឬ ស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងការពន្យារពេលសងបំណុល ឬ លើកលែងអត្រាការប្រាក់ក្នុងឆ្នាំ ២០២១នេះ។ ដែលខុសគ្នាខ្លាំងពីឆ្នាំកន្លងទៅ ដោយពេលនោះមានកសិករចំនួនរហូតដល់ ៤៨.៩ភាគរយ បានដាក់ពាក្យស្នើសុំពន្យារពេលសងក្នុងឆ្នាំ ២០២០។ នៅពេលជាមួយគ្នានេះដែរ កសិករ ៤៨.២ភាគរយ ថាខ្លួនបានលក់ទ្រព្យសម្បត្តិដើម្បីយកប្រាក់ទៅសងបំណុលធនាគារ។ មិនត្រឹមតែប៉ុណ្ណោះ កសិករ ៣២.១ភាគរយ បានទៅខ្ចីប្រាក់ពីបងប្អូន និង៤១.១ភាគរយខ្ចីប្រាក់ពីឯកជនទៅសល់បំណុលដែលខ្លួនមានស្រាប់។

ក្រៅពីការសុំចរចា និងខ្ចីប្រាក់ខាងលើ កសិករខ្នាតតូចចំនួន ៣៥.៧ភាគរយ បានព្យាយាមកាត់បន្ថយចំណាយទៅលើអាហារ និង៤១.១ភាគរយ ព្យាយាមកាត់បន្ថយទៅលើចំណាយនានានៅក្នុងផ្ទះ ដើម្បីសន្សំប្រាក់ទៅសងបំណុលគេវិញ។ ម៉្យាងដោយការសិក្សាពីចម្ងាយរបស់កូនៗ តម្រូវឱ្យមានការចំណាយច្រើនទាំងទៅលើកាតទូរស័ព្ទ និងសម្ភារអេឡិចត្រូនិចនានា កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៨.៩ភាគរយ បានស្នើសុំឱ្យ កូនៗរបស់ពួកគាត់ឈប់រៀន នៅអំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩ នេះ។




*តារាងនេះបង្ហាញពីការប្រៀបធៀបនៃបទពិសោធន៍លំបាករបស់កសិករ*
*និងអ្នកផលិតស្បៀងអាហារខ្នាតតូចក្នុងការសងបំណុលក្នុងឆ្នាំ ២០២០ និងឆ្នាំ ២០២១*

*“ ខ្ញុំមានអារម្មណ៍ពិបាកចិត្ត មិនដឹងថាជាទៅរកលុយមកពីណាដើម្បីសងគេទេ។ ខ្ញុំខ្លាចគេមករឹបអូសដីធ្លី ផ្ទះសំបែងនៅពេលពួកយើងអត់មានអីសងគេ។ ខ្ញុំតែងតែដេក (គេង) យល់សុបិន្តច្រើនពីរឿងបំណុល វាពិតជាប៉ះពាល់មកដល់ផ្លូវចិត្តខ្ញុំណាស់។*

*សម្ដីស្រ្ដីកសិករម្នាក់ជុំវិញបញ្ហាបំណុល ”*

អ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៨៧.៥ភាគរយ មិនទទួលបានការសម្រួលការសងបំណុលត្រឡប់ និងបន្ធូរបន្ថយអាត្រាការប្រាក់ពីធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ថ្វីបើមានកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចមានចំនួនត្រឹមតែ ៥.៨ភាគរយ បានទទួលការសម្របសម្រួលបំណុលពីស្ថាប័នទាំងនេះ។




*តារាងបង្ហាញពីទិន្នន័យបទពិសោធន៍ទទួលបានអន្តរាគមន៍បន្ថែមពីគ្រឹះស្ថានធនាគា និងហិរញ្ញវត្ថុ ដើម្បីគាំពារដល់អតិថិជន*

ការឆ្លើយតបទៅនឹងអន្តរាគមន៍បន្ថែមរបស់គ្រឹះស្ថានធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដើម្បីគាំពារដល់អតិថិជនក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ (ដែលរួមបញ្ចូលការលើកលែងការបង់ការប្រាក់ និងរាល់ការផាកពិន័យរយៈពេលមួយខែ និងពន្យាលពេលបង់ប្រាក់សងរយៈពេលបីខែតាមលក្ខខណ្ឌ) កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួនច្រើនលើសលុប ឬស្មើនឹង ៨៩.៤ភាគរយ មិនបានទទួលការឆ្លើយតប ឬទទួលបានផលប្រយោជន៍ពីកម្មវិធីនេះនៅឡើយទេ។

បំណុលនៅតែចោទជាបញ្ហារ៉ាំរ៉ៃមួយ ដែលបន្តគំរាមគំហែងមកលើជីវភាពរស់នៅរបស់កសិករ ជាពិសេសនៅអំឡុងពេលដែលមានការរាតត្បាតពីជំងឺកូវីដ-១៩។ ការធ្លាក់កាន់តែជ្រៅទៅៗ ក្នុងវដ្តនៃបំណុលនេះកើតឡើងដោយសារតែការបង្ខំចិត្តរបស់ពួកគាត់ដែលសុខចិត្តខ្ចីពីមួយទៅសងមួយដើម្បីតែការរួចខ្លួន និងដោះស្រាយមួយគ្រាសិន។ ជាក់ស្តែង ក្នុងការសិក្សាស្រាវជ្រាវនេះ កសិករមួយចំនួន បានលើកឡើងថាសូម្បីតែបងប្អូន ឬអ្នកដែលស្គាល់គ្នាក៏មិនចង់ និងព្រមឱ្យពួកគាត់ខ្ចីប្រាក់បណ្តោះសិនដើម្បីសងត្រឡប់ទៅធនាគារដែរដោយលើកឡើងថាពួកគាត់ក្រពេកគេខ្លាចថាពួកគាត់មិនមានថវិកាសងត្រឡប់នាថ្ងៃខាងមុខ។ ចំណែកកសិករខ្លះទៀត បានសម្រេចចិត្តខ្ចីប្រាក់ពីបងប្អូន អ្នកជិតខាង ក្រុមសន្សំ និងអ្នកចងការប្រាក់ឯកជនឱ្យរួចមួយខែៗសិនដូចដែលរៀបរាប់ខាងលើ ដោយខ្លាចគេរឹបអូសទ្រព្យសម្បត្តិ និងសម្ភារមានតម្លៃមួយចំនួនទៀត។ បញ្ហាបំណុលបានធ្វើឱ្យកសិករមួយចំនួន បង្ហាញនូវភាពតានតឹង ពិបាកក្នុងចិត្ត ភ័យខ្លាចព្រួយបារម្ភ ជាពិសេសគឺបារម្ភខ្លាចគេរឹបអូសទ្រព្យសម្បត្តិ ឬសម្ភារផ្សេងៗ។ កសិករមួយចំនួនខ្វល់ខ្វាយពេកបានធ្លាក់ខ្លួនឈឺ និងអ្នកខ្លះមានវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរ ដោយរួមទាំងមានអាការៈសម្រាន្តមិនលក់ គិតតែរកវិធីដោះស្រាយបំណុលឱ្យគេ រហូតដល់អ្នកខ្លះទាល់ច្រកគ្មានមធ្យោបាយដោះស្រាយ បានព្យាយាមលេបថ្នាំសម្លាប់ខ្លួនឯង។ ក៏ប៉ុន្តែ វាក៏បានបង្ហាញផងដែរថា អំពើហិង្សានិងជម្លោះក្នុងគ្រួសារបន្តមានកើនឡើងដោយសារតែសមាជិកម្នាក់ៗមានទុក្ខកង្វល់ខ្លាំង ក្នុងចិត្តនឹងលទ្ធភាពសងបំណុលគេ។

## ៦. បញ្ហាទន្ទ្រានដីធ្លី និងធនធានធម្មជាតិ និងបញ្ហាជម្លោះដីធ្លី




*តារាងបង្ហាញពីស្ថានភាពនៃការទន្ទ្រានដីធ្លី ធនធានធម្មជាតិ និងបញ្ហាជម្លោះដីធ្លីក្នុងឆ្នាំ ២០២១*

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំនួន ៤៧.១ភាគរយថា មានករណីរំលោភបំពាននៅអំឡុងពេលពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ហើយសកម្មភាពខុសច្បាប់មួយចំនួននៅតែបន្តកើតមាន ដូចជា ការកាប់ដីបំផ្លាញព្រៃឈើ ព្រៃលិចទឹក និងធនធានធម្មជាតិ ដើម្បីយកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនពីសំណាក់ជនខិលខូច ហើយបញ្ហាការរំលោភបំពានដីធ្លី ការវាយកម្ទេចភ្នំ ការនេសាទខុសច្បាប់ ការត្រូវបានរាយការណ៍ផងដែរ។ មួយវិញទៀត ប្រជាពលរដ្ឋមួយចំនួន ទទួលរងការបណ្តេញចេញពីសំណាក់អាជ្ញាធរក្នុងតំបន់នោះ ដើម្បីយកដីធ្លីនោះទៅបែងចែកឱ្យពលរដ្ឋដទៃទៀតដែលត្រូវបានបណ្តេញចេញមកពីតំបន់មួយផ្សេងទៀត ដែលវាបានធ្វើឱ្យមានផលប៉ះពាល់ទៅដល់ដីធ្លីប្រជាពលរដ្ឋដែលកំពុងតែអាស្រ័យផល។ ក្រៅពីនេះ មានឈ្មួញដើរទិញដីនៅម្តុំអាងស្តុបទឹក ៧៣ក្នុងខេត្តសៀមរាប ដែលជាអាងស្តុកទឹកដ៏សំខាន់សម្រាប់កសិករ ពឹងអាស្រ័យដើម្បីយកទឹកទៅធ្វើស្រែចំការ។ ឈ្មួញបានបន្តចាប់ផ្តើមទន្ទ្រានយកដីអាងនេះ ដើម្បីធ្វើជាកម្មសិទ្ធិរបស់ខ្លួនម្តងបន្តិចៗ។

ការទន្ទ្រានយកដីព្រៃលិចទឹករបស់រដ្ឋមកធ្វើជាកម្មសិទ្ធិបុគ្គល ដែលជាកន្លែងហាមឃាត់ដែលធ្វើឱ្យបាត់បង់ព្រៃលិចទឹកសម្រាប់មច្ឆជាតិ។ ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ដូចជាប្រើឃ្មុំងការ ឧបករណ៍ឆក់ បរណាវ៉ា និងលូស្បៃមុង ដែលជាកន្លែងមច្ឆជាតិពងនៅតែបន្តទទួលរងការបំផ្លិចបំផ្លាញជាបន្តបន្ទាប់ ដែលការណ៍នេះ ធ្វើឱ្យបាត់បង់ពូជត្រីកម្រមួយចំនួននៅក្នុងតំបន់ការពារ។ ករណីឈូសឆាយយកដីព្រៃសហគមន៍ នៅអំឡុងពេលដែលពួកគាត់មិនអាចចុះល្បាតដោយសារមានការហាមឃាត់ការជួបជុំជាដើម។ ទោះបីជា មានការរាយការណ៍ពីកសិករ ឬសហគមន៍មូលដ្ឋានទៅដល់អាជ្ញាធរ ប៉ុន្តែហាក់ពុំសូវមានមានការមិនយកចិត្តទុកដាក់ឆ្លើយតបពីពួកគេនៅឡើយទៅលើបញ្ហាទាំងនោះ។

ចំណែកឯការប្តឹងទាមទាររកដំណោះស្រាយរបស់ប្រជាពលរដ្ឋមួយចំនួន ក៏ត្រូវបានផ្អាកដំណើរការដោយបញ្ហាការរាតត្បាតនៃជំងឺកូវីដ-១៩។ ផ្ទុយទៅវិញ បើទោះជាវិបត្តិពីការរាតត្បាតនៃកូវីដ-១៩ នៅតែបន្តកើនឡើងក្នុងប្រទេសយ៉ាងណាក្តី យើងអាចកត់សម្គាល់ឃើញថា មានដីការចេញពីតុលាការដោយមានការចោទប្រកាន់សមាជិកសហគមន៍ ដែលជាអ្នកការពារដីធ្លីរបស់ខ្លួន និងធនធានធម្មជាតិដែលក្រុមហ៊ុនជាអ្នករំលោភបំពាន និងឈូសឆាយដីធ្លីរបស់ពួកគាត់។ បច្ចុប្បន្ននេះសហគមន៍ កំពុងតែសហការជាមួយមេធាវីដើម្បីស្នើសុំការពន្យាពេលទៅឆ្លើយបំភ្លឺនៅតុលាការ។ កសិករនិងអ្នកផលិតស្បៀងអាហារមួយចំនួនសង្កេតឃើញថា ការរឹតត្បិតការជួបជុំនិងសកម្មភាពការពារធនធានទាំងនេះ ដោយលើកឡើងនូវក្តីបារម្ភពីការរាតត្បាតពីជំងឺកូវីដ-១៩ បានបង្កើតជាឱកាសដល់ជនល្មើស ឬក្រុមហ៊ុនខិលខូចមួយចំនួន ក្នុងការទន្ទ្រានយកដីព្រៃសហគមន៍ និងបំផ្លាញធនធានធម្មជាតិជាដើម។




*តារាងបង្ហាញពីបទពិសោធន៍របស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចចំពោះការរងនូវការបៀតបៀន ការរើសអើង និងអំពើហិង្សាក្រោមរូបភាពផ្សេងៗក្នុងអំឡុងពេលការរាតត្បាតនៃជំងឺកូវីដ-១៩*

កសិករខ្នាតតូច ៤៣.៣ភាគរយ ទទួលរងការបៀតបៀន ការរើសអើង ឬអំពើហិង្សាទាំងលើខ្លួនពួកគាត់ ឬមានសមាជិកក្នុងគ្រួសាររបស់ពួកគាត់ដែលធ្លាប់ទទួលរងអំពើទាំងនេះ នៅក្នុងអំឡុងពេលនៃការរាតត្បាតពីជំងឺកូវីដ-១៩។ សកម្មភាពនៃការបៀតបៀន ការរើសអើង ឬអំពើហិង្សាមានទម្រង់ខុសៗគ្នា។ កសិករមួយចំនួនថា ការរើសអើងកើតឡើងនៅពេលដែលសមាជិកគ្រួសាររបស់ពួកគាត់មានជំងឺគ្រុនក្ដៅសាយ ហើយជាពិសេសអ្នកដែលមានសមាជិកនៅទីក្រុងភ្នំពេញ ត្រូវបានអាជ្ញាធរបញ្ជូនយកទៅធ្វើចត្តាឡីស័ក។ កសិករមួយចំនួនថាលើកឡើងថា ការស្វែងរកសេវាសាធារណៈដូចជារៀបចំ ឬមានតម្រូវការឯកសាររដ្ឋបាល និងពេលមានប្រជាពលរដ្ឋណាម្នាក់ឈឺដែលតម្រូវឱ្យមានការប្រើប្រាស់សេវាទាំងនោះ ទាំងបុគ្គលិកសុខាភិបាល និងគ្រូពេទ្យដែលបម្រើការងារនៅមន្ទីរពេទ្យ ឬគ្លីនីកឯកជន ឬបុគ្គលិកសាធារណៈមួយចំនួនមិនចង់សម្របសម្រួល ឬព្យាបាលពួកគាត់ទេដោយសារខ្លាចឆ្លងជំងឺកូវីដ-១៩។ ក្រៅពីនេះ សមាជិកសហគមន៍មួយចំនួនដែលមានផ្ទុកជំងឺអេដស៍ ឬអ្នករស់នៅជាមួយជំងឺអេដស៍ជួបប្រទះការរើសអើង និងពុំទទួលបានការយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរ។

ការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ នៅអំឡុងពេលនៃការរាតត្បាតពីជំងឺកូវីដ-១៩ បន្តកើតមាន និងមានការកើនឡើង ដោយសារ សមាជិកគ្រួសារគ្មានការងារមិនមាន ប្រាក់ចំណូលរួមជាមួយភាពស្មុកស្មាញ និងតានតឹងមួយចំនួនទៀត។

ក្រៅពីបម្រាម និងការរឹតត្បិតការជួបជុំនានារបស់សហគមន៍ដើម្បីទប់ស្កាត់នូវការរីករាលដាលនៃជំងឺកូវីដ-១៩ កសិករមួយចំនួន ពិសេសដែលស្ថិតនៅក្នុងបញ្ហាទំនាស់ដីធ្លី នៅបន្តទទួលរងការចោទប្រកាន់ពេលដែលពួកគេព្យាយាមប្រមូលផ្តុំទាមទារសិទ្ធិដីធ្លី សំណាង និងយុត្តិធម៌ក្រោមការចោទប្រកាន់ថាជាក្រុមអ្នកប្រឆាំង។



*រូបភាពបង្ហាញពីការចូលទៅរកអនុផលព្រៃឈើ ក្នុងខេត្តឧត្តរមានជ័យ*

## ៧. សេចក្ដីសន្និដ្ឋាន

ផលប៉ះពាល់ពីវិបត្តិនានាដែលស្ដែងចេញពីការរាតត្បាតនៃជំងឺកូវីដ-១៩ ទៅលើកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច បន្តមានភាពធ្ងន់ធ្ងរ។ ផលប៉ះពាល់ មានជាអាទិ៍ទាំងបញ្ហាកង្វះស្បៀងអាហារ ការកាត់បន្ថយគុណភាព ឬបរិមាណអាហាររបស់កសិករ បញ្ហាការធ្លាក់ចូលទៅក្នុងវដ្តនៃបំណុល និងភាពក្រីក្រ។ បញ្ហាបំណុលត្រូវបានអង្កេតឃើញថា មានការកើនឡើងក្នុងចំណោមកសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចពីមួយឆ្នាំទៅមួយឆ្នាំ ដោយបូករួមទាំងបញ្ហាលំបាកក្នុងការសងបំណុលត្រឡប់ និងវដ្តនៃបំណុលផងដែរ។ មិនមានភស្តុតាងណាមួយ បញ្ជាក់ពីប្រសិទ្ធិភាព ពីការលើកលែង ឬសម្រួលការសងបំណុលត្រឡប់ពីសំណាក់កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូច ដោយស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬធនាពាណិជ្ជព្រមទាំងពីរដ្ឋាភិបាលក្នុងវិបត្តិនៃការរាតត្បាតពីជំងឺកូវីដ-១៩ នៅក្នុងការស្រាវជ្រាវនេះ។ កសិករខ្នាតតូចជាច្រើន បន្តព្យាយាមគ្រប់លទ្ធភាពស្វះស្វែងសងបំណុលត្រឡប់ទៅកាន់ស្ថាប័នទាំងនេះ បើទោះបីក្នុងករណីខ្លះពួកគាត់ត្រូវបង្ខំចិត្តជម្រុញឱ្យកូនៗបោះបង់ចោលការសិក្សា ឬកាត់បន្ថយការចំណាយប្រចាំថ្ងៃទាំងការចំណាយទៅលើអាហារជាដើម។

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចជាច្រើន ក៏នៅបន្តជួបប្រទះនិងទទួលរងគ្រោះចំពោះការចំណាយច្រើនទៅលើធាតុចូល និងសម្ភារសម្រាប់បង្ករបង្កើនផល ដែលវាផ្ទុយពីផលដែលពួកគាត់បានទទួលត្រឡប់នាពេលប្រមូលកសិផល។ តម្លៃកសិផលបន្តត្រូវបានគ្រប់គ្រងកំណត់ដោយអ្នកទិញ ឬឈ្មួញកណ្ដាល ឬរោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុនកសិ-ឧស្សាហកម្មដដែល។ កសិករភាគច្រើនមិនមានភាពជាម្ចាស់ ឬអំណាចទៅលើការកំណត់តម្លៃកសិផលដែលខ្លួនបានផលិតនោះទេ។ ការហូរចូលនៃកសិផលពីក្រៅប្រទេស ពិសេសពីប្រទេសជិតខាង បន្តផ្ដល់ផលប៉ះពាល់ដល់កសិផលដែលផលិតបានដោយកសិករខ្នាតតូចក្នុងស្រុក ហើយកសិផលទាំងនោះទៀតសោត បន្តមានតម្លៃថ្លៃជាងតម្លៃកសិផលរបស់កសិករក្នុងស្រុក។ ស្របពេលដែលកសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចក្នុងស្រុកមិនទទួលបានការគាំទ្របច្ចេកទេស ការឧបត្ថម្ភធន សម្របសម្រួលឬធានាទីផ្សារសម្រាប់កសិករ។ កសិករខ្នាតតូចទទួលបានការសម្របសម្រួលឬការគាំទ្រទុនតិចតួចណាស់មិនថាក្នុងទម្រង់ជាកម្ចី ឬជាការគាំទ្រធនជាលក្ខណៈប្រព័ន្ធ សម្រាប់ការវិនិយោគ។ តួយ៉ាង កសិករចំនួនតិចតួចណាស់ដែលបានទទួលការ គាំទ្រពីគម្រោងក្នុងអំឡុងពេលនៃការរាតត្បាតពីជំងឺកូវីដ-១៩។

ដោយសារបញ្ហាការចំណាយច្រើនទៅលើធាតុចូលផលិតផលកសិកម្ម និងបញ្ហាធ្លាក់ចុះនៃតម្លៃកសិផល កសិករមួយចំនួនសម្រេចផ្អាកធ្វើស្រែចំការក្នុងអំឡុងឆ្នាំ ២០២១។ ឆ្លើយតប ព្រមទាំងយន្តការដោះស្រាយ និងការគាំទ្រដែលបានដាក់ចេញដោយរដ្ឋាភិបាល ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ហាក់មិនទាន់បានឆ្លើយតបទៅនឹងបញ្ហាប្រឈម ឬដោះស្រាយផលប៉ះពាល់ដែលកសិករនិងអ្នកផលិតស្បៀងអាហារបន្តជួបប្រទះនៅឡើយនោះទេ ក្នុងនោះដូចជា នៅមិនទាន់មានការគាំទ្រឱ្យបានទូលំទូលាយទៅលើដល់

គ្រួសារកសិករក្រីក្រជាសាច់ប្រាក់ ការសម្របសម្រួលការសងបំណុលត្រឡប់ទៅធនាគារពាណិជ្ជ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ ការគ្រប់គ្រងតម្លៃស្បៀងអាហារ និងទំនិញនៅលើទីផ្សារដោយរួមទាំងតម្លៃធាតុចូលនៃការធ្វើកសិកម្ម តម្លៃប្រេងឥន្ធនៈ បើធៀបទៅនឹងការធ្លាក់ចុះយ៉ាងគំហុកនៃតម្លៃ កសិផលរបស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច។

រីឯបញ្ហាចម្បងមួយទៀតដែលកសិករបន្តជួបប្រទះធ្ងន់ធ្ងរជាងមុន គឺការមិនទទួលបានការថែទាំយកចិត្តទុកដាក់កាលៈទេសៈ មានជំងឺធ្ងន់ធ្ងរដែលអាចបណ្តាលឱ្យប៉ះពាល់ដល់អាយុជីវិតរបស់សមាជិកគ្រួសារពួកគាត់ ពីសំណាក់ក្រសួងពាក់ព័ន្ធ ពិសេសជុំវិញការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវា។ បន្ទុកការចំណាយបន្ថែមបានធ្លាក់ទៅលើកសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូច។ បន្ទុកទាំងនោះមានទាំងការចំណាយទៅលើសម្ភារការពារខ្លួន ការធ្វើតេស្តរកមេរោគកូរ៉ូណា ឬជំងឺកូវីដ-១៩ ពេលទៅប្រើប្រាស់សេវាព្យាបាល ព្រមទាំងបន្ថែមបន្ទុកទៅលើការចំណាយសម្រាប់កសិករខ្នាតតូច។

បន្ថែមទៅលើកម្រិតភាពនៃការដោះស្រាយបញ្ហា ឬការផ្តល់ការគាំទ្ររបស់រដ្ឋាភិបាល ចំពោះកសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចដែលរងគ្រោះ ការដាក់ចេញឱ្យអនុវត្តវិធាន ការតាក់តែងនិងអនុម័តច្បាប់ សេចក្តីសម្រេច និងការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមួយចំនួនធ្វើឡើងយ៉ាងឆាប់រហ័ស ដោយមិនបានបញ្ចូលកិច្ចពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាសាធារណៈ ឬក៏សិក្សាអំពីផលប៉ះពាល់របស់វាជាលក្ខណៈអវិជ្ជមានជាមុន។

កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចទទួលស្គាល់ និងកោតសសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសុខាភិបាល ក្រសួងពាក់ព័ន្ធមួយចំនួន ព្រមទាំងអាជ្ញាធរមូលដ្ឋាន។ ទោះជាយ៉ាងនេះក្តី សេចក្តីសម្រេច និងការដាក់ចេញឱ្យអនុវត្តវិធានទាំងវិធានរដ្ឋបាល វិធានសុខាភិបាល និងវិធានផ្សេងៗមួយចំនួន ក៏បានផ្តល់ផលប៉ះពាល់និងផលលំបាកដល់ជីវភាពរស់នៅដែលធ្វើឱ្យកសិករមួយចំនួនធ្លាក់ចុះជីវភាពដោយសារការបាត់បង់ប្រាក់ចំណូលភ្លាមៗ និងបញ្ហាលំបាកក្នុងការសងបំណុលត្រឡប់ទៅធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

វិបត្តិដែលបង្ករឡើងពីបម្រែបម្រួលអាកាសធាតុ បានជម្រុញឱ្យកសិករខ្នាតតូច ខាតបង់ថវិកា ឬបាត់បង់ជីវភាពដោយសារការបំផ្លិចបំផ្លាញស្ទើរទាំងស្រុង នៃកសិផលរបស់ពួកគាត់ដោយសារគ្រោះទឹកជំនន់ និងរាំងស្ងួត នាអំឡុងពេលពីរឆ្នាំជាប់ៗគ្នា។ ផលប៉ះពាល់នេះ បណ្តាលឱ្យកសិករមួយចំនួនពិចារណាក្នុងការផ្អាកធ្វើកសិកម្មមួយរយៈដោយសារការចំណាយច្រើន ហើយមិនទទួលបានផលត្រឡប់មកវិញ។

តម្រូវការរបស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចមិនទាន់ត្រូវបានដោះស្រាយ ឬឆ្លើយតបពីសំណាក់រដ្ឋាភិបាល ក្រសួង និងស្ថាប័នពាក់ព័ន្ធមួយចំនួនជាលក្ខណៈបន្ទាន់ និងជាលក្ខណៈប្រព័ន្ធនៅឡើយនោះទេ។ ផងដែរ ដោយសារផលប៉ះពាល់ពីវិបត្តិនានាពីការរាតត្បាតនៃជំងឺកូវីដ-១៩ មកលើកសិករមានភាពធ្ងន់ធ្ងរ ការស្តារឡើងវិញនូវជីវភាពរបស់ពួកគាត់ មានសារៈសំខាន់ដែលត្រូវការការគាំទ្រ

ជាចាំបាច់ និងជាការបន្ទាន់។ ការឆ្លើយតប និងការស្តារឡើងវិញទៅលើជីវភាពរបស់កសិករ គឺគួរត្រូវដោះស្រាយទាំងជាលក្ខណៈប្រព័ន្ធ ដោយសារបញ្ហាទាំងនោះបន្តកើតមានឡើងហើយវាមានភាពរ៉ាំរ៉ៃ ជាអាទិ៍បញ្ហាកង្វះការគាំទ្រការឧបត្ថម្ភធនដល់កសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូចក្នុងដំណើរការផលិត បញ្ហាវដ្តនៃបំណុល និងបញ្ហាអត្រាការប្រាក់ខ្ពស់ពីប្រាក់កម្ចីពីធនាគារពាណិជ្ជ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ ព្រមទាំងការមិនលើកលែងបំណុលបើទោះបីជាកសិករស្ថិតក្នុងស្ថានភាពលំបាក បញ្ហាការគ្រប់គ្រងការកំណត់តម្លៃទីផ្សារពីឈ្មួញ ឬអ្នកទិញ និងបញ្ហាកម្រិតភាពនៃប្រព័ន្ធកិច្ចគាំពារសង្គមចំពោះកសិករ ជាដើម។ល។

## ៨. សំណូមពរ តម្រូវការ និងអនុសាសន៍

### ជូនរដ្ឋាភិបាល ក្រសួងនិងស្ថាប័នពាក់ព័ន្ធនានា

១. ស្នើរដ្ឋាភិបាលបន្តផ្តល់វ៉ាក់សាំងការពារ និងឱសថព្យាបាលជំងឺកូវីដ-១៩ និងឱសថពាក់ព័ន្ធដទៃទៀត ដោយឥតបង់ថ្លៃ និងប្រកបដោយប្រសិទ្ធិភាពដល់កសិករ និងប្រជាពលរដ្ឋទូទៅ
២. ស្នើរដ្ឋាភិបាលបន្តគាំទ្រផ្តល់សេវាថែទាំ និងព្យាបាលជំងឺកូវីដ-១៩ ដោយឥតបង់ថ្លៃ និងមានគុណភាព សម្រាប់កសិករខ្នាតតូចនិងប្រជាពលរដ្ឋគ្រប់រូប
៣. ស្នើរដ្ឋាភិបាលដោះស្រាយ និងសម្របសម្រួល លើកលែងការសងត្រឡប់ទៅកាន់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បីជួយសម្រួល និងស្តារជីវភាពរបស់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាត តូចឡើងវិញបន្ទាប់ពីការរាតត្បាតនៃជំងឺកូវីដ-១៩
៤. ស្នើរដ្ឋាភិបាលជម្រុញឱ្យមានការទម្លាក់អត្រាការប្រាក់ និងលក្ខខណ្ឌពីកម្ចីធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
៥. ស្នើរដ្ឋាភិបាលផ្តល់ការគាំទ្រសម្ភារការពារខ្លួនដល់គ្រួសារកសិករខ្នាតតូចដើម្បីកាត់បន្ថយការចំណាយដែលជាបន្ទុកចំពោះកសិករ
៦. ស្នើរដ្ឋាភិបាលទប់ស្កាត់បទល្មើសការរំលោភដីធ្លី ការបំផ្លិចបំផ្លាញធនធានធម្មជាតិនានា នាអំឡុងពេល និងក្រោយអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩
៧. ស្នើរដ្ឋាភិបាលបង្កើតកម្មវិធីឧបត្ថម្ភធន និងគាំទ្របច្ចេកទេសផ្នែកកសិកម្មដល់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច (ដូចជា៖ ពូជស្រូវ ពូជដំណាំពីបុរាណ ទឹក ដើមទុន និងទីផ្សារជាដើម។)
៨. ស្នើរដ្ឋាភិបាលផ្តល់ការគាំទ្រស្បៀងអាហារ និងកិច្ចគាំពារសង្គមដល់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូចឱ្យបានទូលំទូលាយ
៩. ស្នើឱ្យតុលាការទម្លាក់ចោលបទចោទប្រកាន់ និងលើកលែងការកោះហៅបន្តចំពោះសកម្មជនដីធ្លី
១០. ស្នើរដ្ឋាភិបាលគ្រប់គ្រង តម្លៃប្រេងសាំង និងទំនិញនៅលើទីផ្សារ
១១. ស្នើរដ្ឋាភិបាលសិក្សា និងផ្តល់គាំទ្រពិតប្រាកដដល់កសិករខ្នាតតូច
១២. ស្នើរដ្ឋាភិបាលពន្លឿនដោះស្រាយបញ្ហាដីធ្លីជូនកសិករ និងអ្នកផលិតស្បៀងអាហារខ្នាតតូច
១៣. ស្នើឱ្យមានការផ្សព្វផ្សាយព័ត៌មានពីការវិវឌ្ឍនៃការរាតត្បាតនៃជំងឺកូវីដ-១៩ ឱ្យបានទូលំទូលាយ
១៤. ស្នើរដ្ឋាភិបាលរៀបចំកិច្ចពិគ្រោះយោបល់ជាមួយពលរដ្ឋរួមទាំង កសិករ អ្នកនេសាទ ជនជាតិដើមភាគតិច សមាគមន៍ អង្គការ ឬអ្នកពាក់ព័ន្ធនានាជាមុន នៅពេលមានការតាក់តែង
១៥. ស្នើរដ្ឋាភិបាលគ្រប់គ្រងនិងធ្វើឱ្យមានតុល្យភាពនៃតម្លៃកសិផលដែលផលិតបានដោយកសិករខ្នាតតូចក្នុងស្រុកទៅនឹងតម្លៃកសិផលដែលនាំចូល
១៦. ស្នើកុំមានការរើសអើងចំពោះសហគមន៍ដីធ្លី ជាពិសេសជនរងគ្រោះដីធ្លីនៅក្នុងវិបត្តិជំងកូវីដ-១៩

១៧. ស្នើរដ្ឋាភិបាលផ្តល់ដីសង្គមកិច្ចសម្រាប់ការដាំដុះអាស្រ័យផលសម្រាប់គ្រួសារកសិករខ្នាតតូច
១៨.ស្នើឱ្យមានការបន្ធូរបន្ថយ ឬការលើកលែងទៅលើការចំណាយទឹក ភ្លើងដែលផ្គត់ផ្គង់ដោយរដ្ឋាករទឹក និងអគ្គីសនីស្វយ័តកម្ពុជា

## អនុសាសន៍ និងសំណើររបស់ប្រជាកសិករ

១. ទទូចឱ្យរដ្ឋាភិបាលបន្តផ្តល់វ៉ាក់សាំងការពារ ឱសថពាក់ព័ន្ធ និងការព្យាបាលជំងឺកូវីដ-១៩ ដោយឥតគិតថ្លៃ និងមានប្រសិទ្ធិភាព
២. ទទូចឱ្យរដ្ឋាភិបាលត្រៀមកញ្ចប់ថវិកាសម្រាប់គាំទ្រស្បៀងជួយអ្នកងាយរងគ្រោះពិតប្រាកដឱ្យបានទូលំទូលាយ និងប្រកបដោយប្រសិទ្ធិភាព
៣. ទទូចដល់រដ្ឋាភិបាលអន្តរាគមន៍ចំពោះបញ្ហាបំណុលជាមួយធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដោយសារបញ្ហានេះបន្តជាបញ្ហារ៉ាំរ៉ៃសម្រាប់កសិករនិងអ្នកផលិតស្បៀងអាហារខ្នាតតូច
៤. ផ្តល់ការឧបត្ថម្ភធនដល់កសិករខ្នាតតូច ដូចជា ពូជបុរាណ ទុន សម្ភារ និងប្រព័ន្ធធារាសាស្ត្រ
៥. កាត់បន្ថយការឧបត្ថម្ភធនដល់ក្រុមហ៊ុនធំៗ ពីសំណាក់រដ្ឋាភិបាល និងផ្តល់ការគាំទ្រដល់កសិករខ្នាតតូចជំនួសវិញ
៦. ធ្វើវិសោធនកម្មច្បាប់ស្តីពី វិធានទប់ស្កាត់ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវធ្ងន់ធ្ងរផ្សេងទៀត
៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរយកចិត្តទុកដាក់ និងជម្រុញឱ្យមានការអនុវត្តកសិកម្មបែបធម្មជាតិ ឬកក្សេតបរិស្ថានដើម្បីនិរន្តរភាពបរិស្ថាន សុខភាពមនុស្ស និងប្រព័ន្ធអេកូឡូស៊ី
៨. បង្កើតការងារដែលមានលក្ខខណ្ឌល្អប្រសើរ និងមានប្រាក់បៀវត្សសមរម្យសម្រាប់ពលរដ្ឋនៅក្នុងសហគមន៍មូលដ្ឋានដើម្បីបញ្ចៀស ឬកាត់បន្ថយការចំណាកស្រុកទៅក្រៅប្រទេស
៩. គាំទ្របច្ចេកទេសដាំដុះដល់កសិករខ្នាតតូចពិសេសផ្តោតលើការដាំដុះបែបក្សេត្របរិស្ថាន
១០. លើកកម្ពស់កសិកម្មបែបធម្មជាតិ ឬបែបក្សេត្របរិស្ថានជាជាងទំនើបកម្ម (លើកទឹកចិត្តជនអភិរក្សវប្បធម៌ និងធនធានធម្មជាតិ) ហើយយកបច្ចេកទេសជួយធម្មជាតិជាជាងបំផ្លាញធម្មជាតិ

## ៩. ឯកសារយោង

### ច្បាប់ និងឯកសារបទដ្ឋានគតិយុត្តិ

១. សេចក្តីជូនដំណឹង លេខ ០០៦/២១ សណន ចុះថ្ងៃចន្ទ ៨រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ថ្ងៃទី៥ ខែមេសា ឆ្នាំ ២០២១ ស្តីពី ការរឹតបន្តឹងការអនុវត្តវិធានសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ និងវិធានការបង្ការ-ទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ នៅក្នុងឱកាសឈប់សម្រាកនៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ https://khmerpostasia.com/archives/69822 (ចូលមើលថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២១)

២. សេចក្តីជូនដំណឹង លេខ០៤២/២១ សណន ចុះថ្ងៃចន្ទ ៨រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២១ ស្តីពី វិធានការរដ្ឋបាលជាបណ្តោះអាសន្នរយៈពេល ០៩ ថ្ងៃ ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២១ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នាឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ក្នុងភូមិសាស្ត្រខេត្តកំពង់ធំ https://kampongthom.gov.kh/14888/ (ចូលមើលថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២១)

៣. សេចក្តីជូនដំណឹង លេខ១១៤ ស.ជ.ណ ចុះថ្ងៃចន្ទ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក គ.ស១៩៦៤ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០២០ ស្តីពី ការបិទដំណើរការជាបណ្តោះអាសន្នពីរសប្តាហ៍ រោងភាពយន្ត រោងសម្តែងសិល្បៈ និងសារមន្ទីរទូទាំងប្រទេស https://khmerpostasia.com/archives/61355 (ចូលមើលថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០២១)។

៤. សេចក្តីជូនដំណឹង លេខ ៨០ អយក.សជណ ចុះថ្ងៃចន្ទ ៧រោច ខែមិគសិរ ឆ្នាំជូត ទោស័ក គ.ស១៩៦៤ ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០២០ ស្តីពី ការពន្យារពេលនៃការប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា ២០១៩-២០២០ ដែលគ្រោងរៀបចំនៅថ្ងៃទី ២១ និងទី ២២ ខែធ្នូ ឆ្នាំ ២០២០ ទៅពាក់កណ្តាលខែ មករា ឆ្នាំ ២០២១ វិញដោយក្រសួងនឹងជូនដំណឹងអំពីកាលបរិច្ឆេទច្បាស់លាស់នៃការប្រឡងនៅពេលក្រោយ https://opendevelopmentcambodia.net/wp_content/blogs.dir/2/files_mf/1607394516130697661_4249596218400293_8998862098487098238_o.jpg (ចូលមើលថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០២១)

៥. សេចក្តីជូនដំណឹង លេខ ៧៣ អយក.សជណ ចុះថ្ងៃចន្ទ ១៥កើត ខែមិគសិរ ទោស័ក ព.ស ១៩៦៤ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០២០ ស្តីពី ការផ្អាកសកម្មភាពជួបជុំ រយៈពេល ១៥ ថ្ងៃនៅរាជធានីភ្នំពេញ និងខេត្តសៀមរាប https://www.cpp.org.kh/details/250652 (ចូលមើលថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០២១)។

៦. សេចក្តីជូនដំណឹង លេខ ២៤ អយក.សជណ ចុះថ្ងៃពុធ ១២រោច ខែផល្គុន ជូត ទោស័ក

ព.ស ១៩៦៤ ថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០២១ ស្តីពី ការផ្អាកដំណើរការគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ជាបណ្តោះអាសន្ននៅទូទាំងខេត្តព្រៃវែងដំណឹង ដោយគ្រឹះស្ថានសិក្សា ទាំងអស់ត្រូវបន្តដំណើរការបង្រៀន និងរៀនតាមប្រព័ន្ធអេឡិចត្រូនិច https://opendevelopmentcambodia.net/wpcontent/blogs.dir/2/files_mf/1615445053MoEYS_11032021.jpg (ចូលមើលថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០២១)។

៧. សេចក្តីជូនដំណឹង លេខ ៤៦២ សជណ.អគខ ចុះថ្ងៃចន្ទ ១១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ១៩៦៥ ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០២១ ស្តីពី ការអនុញ្ញាតឱ្យទេសចរណ៍អន្តរជាតិ និងអ្នកដំណើរដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញចូលក្នុងព្រះរាជាណាក្រកម្ពុជាដោយមិនតម្រូវឱ្យធ្វើចត្តាឡីស័ក https://opendevelopmentcambodia.net/wp-content/blogs.dir/2/files_mf/16370291198.jpg (ចូលមើលថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០២១)។

៨. អនុក្រឹត្យ លេខ ៥៧ អនក្រ.ម.ក ចុះថ្ងៃពុធ ៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២១ ស្តីពី វិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការរីករាលដាលឆ្លងនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត https://cambodia-police.com/policekh/273972 (ចូលមើលថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២១)

៩. អនុក្រឹត្យ លេខ ៦៦ អធក្រ.ម.ក ចុះថ្ងៃអាទិត្យ ១៤រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០២១ ស្តីពីកាតព្វកិច្ចក្នុងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩https://www.mpwt.gov.kh/kh/documents/sub-decree/400 (ចូលមើលថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២១)

១០. សេចក្តីសម្រេចលេខ ០៩៨/២១ សសរ.ច ចុះថ្ងៃអាទិត្យ ៧កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៤ ថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០២១ ស្តីពី ការពិន័យអន្តរការណ៍ចំពោះបុគ្គលដែលមិនគោរពដោយចេតនាវិធានការរដ្ឋបាល ក្នុងការទប់ស្កាត់ការរីករាលដាលឆ្លងនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ https://www.moj.gov.kh/kh/news-event/782 (ចូលមើលថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២១)

១១. សេចក្តីសម្រេចលេខ ៤៤សសរ ចុះថ្ងៃអង្គារ ៩រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ថ្ងៃទី ៦ ខែមេសា ឆ្នាំ ២០២១ ស្តីពីការហាមឃាត់ការធ្វើដំណើរ និងការបិទរមណីយដ្ឋានទេសចរណ៍នៅទូទាំងប្រទេសជាបណ្តោះអាសន្នដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ https://www.moj.gov.kh/kh/news-event/782 (ចូលមើលថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២១)

១២. សេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបន្តបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ https://phnompenh.gov.kh/news-press-releases/post/an-n270421a/ (ចូលមើលថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ២០២១)

១៣. សេចក្តីជូនដំណឹងស្តីពី ភូមិសាស្ត្រដែលត្រូវអនុវត្តកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពhttps://niph.org.kh/niph/uploads/library/pdf/LD278_%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%9F%E1%9E%BD%E1%9E%84%E1%9E%80%E1%9F%86%E1%9E%8E%E1%9E%8F%E1%9F%8B%E1%9E%B1%E1%9F%92%E1%9E%99%E1%9E%9A%E1%9E%B6%E1%9E%87%E1%9E%92%E1%9E%B6%E1%9E%93%E1%9E%B8%E1%9E%97%E1%9F%92%E1%9E%93%E1%9F%86%E1%9E%96%E1%9F%81%E1%9E%89_%E1%9E%96%E1%9F%92%E1%9E%9A%E1%9F%87%E1%9E%9F%E1%9E%B8%E1%9E%A0%E1%9E%93%E1%9E%BB_%E1%9E%80%E1%9E%8E%E1%9F%92%E1%9E%8A%E1%9E%B6%E1%9E%9B_%E1%9E%96%E1%9F%92%E1%9E%9A%E1%9F%83%E1%9E%9C%E1%9F%82%E1%9E%84_%E1%9E%93%E1%9E%B7%E1%9E%84%E1%9E%9F%E1%9F%80%E1%9E%98%E1%9E%9A%E1%9E%B6%E1%9E%94.pdf

១៤. រដ្ឋបាលសៀមរាប លេខ ០៩០/២១ សសរ សេចក្តីសម្រេចស្តីពី ការបន្តអនុវត្តវិធានការរដ្ឋបាលជាណ្តោះអាសន្ន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងភូមិសាស្ត្រខេត្តសៀមរាប អភិបាលនៃគណៈអិបាលខេត្តសៀមរាប https://siemreap.gov.kh/detail/16086

១៥. រដ្ឋបាលរាជធានីភ្នំពេញ លេខ ១២១/២១ សសរ សេចក្តីសម្រេចស្តីពី ការដាក់ចេញនូវវិធានរដ្ឋបាល ដោយផ្អាកជាបណ្តោះអាសន្នចំពោះសកម្មភាពការងារ មុខរបរ ឬអាជីកម្មដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងការជួបជុំ ឬការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជន នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ សម្រាប់រយៈពេល ១៤ថ្ងៃ គិតចាប់ពីម៉ោងសូន្យ នាថ្ងៃទី០៣ រហូតដល់ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០២១https://phnompenh.gov.kh/news-press-re-leases/post/ann03621m/

១៦. រដ្ឋបាលខេត្តបន្ទាយជ័យ លេខ ២៦៨/២១ សសរ សេចក្តីសម្រេចស្តីពី ការអនុវត្តវិធានការរដ្ឋបាលបណ្តោះអាសន្ន ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ file:///Users/macbook/Downloads/%EB%B0%98%ED%85%8C%EC%9D%B4%EB%AF%BC%EC%B2%B4%EC%9D%B4%EC%A3%B-C%EC%A0%95%EB%B6%80%20%EC%A0%9C268%ED%98%B8%20%EA%B2%B0%EC%A0%95%EB%AC%B8.pdf

១៧. ច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត https://www.interior.gov.kh/document/detail/1033

១៨. ក្រសួងសុខាភិបាល លេខ ០៧៨ សនក សេចក្តីសម្រេចស្តីពី ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពី វិធានសុវត្ថិភាពផ្នែកសុខាភិបាលទាក់ទងនឹងការគ្រប់គ្រង និងចាត់ចែងសាកសពដែល

មានផ្ទុកមេរោគកូវីដ-១៩https://niph.org.kh/niph/uploads/library/pdf/GL246_guidelines_disposition_of_corpse_covid19.pdf

១៩. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងប្រយុទ្ធនឹងជំងឺកូវីដ-១៩http://mosvy.gov.kh/%E1%9E%80%E1%9E%98%E1%9F%92%E1%9E%98%E1%9E%9C%E1%9E%B7%E1%9E%92%E1%9E%B8%E1%9E%A7%E1%9E%94%E1%9E%8F%E1%9F%92%E1%9E%90%E1%9E%98%E1%9F%92%E1%9E%97%E1%9E%9F%E1%9E%B6%E1%9E%85%E1%9F%8B%E1%9E%94%E1%9F%92-4/

២០. ក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា សេចក្តីជូនដំណឹងស្តីពី លទ្ធផលនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងកូវីដ-១៩ សម្រាប់ខែមិថុនា https://docs.google.com/viewerng/viewer?url=https://opendevelopmentcambodia.net/wp-content/blogs.dir/2/files_mf/1595821837jpg2pdf5.pdf

២១. សេចក្តីថ្លែងការណ៍រួម អំពីអន្តរាគមន៍បន្ថែមរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដើម្បីគាំពារដល់អតិថិជនក្នុងអំឡុងពេលរីករាលនៃជំងឺកូវីដ-១៩ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០២១ https://www.abc.org.kh/news/secktiithlaengkaarnnruam-qmbii-qntraagmnpnthaemrpsgry-hsthaandhnaagaar-ninghirnynyvtthu

២២. ព្រះរាជក្រម នស/រកម/១០២១/០១៤ ប្រកាសឱ្យប្រើច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ ២០២១ នាម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ https://www.coj.gov.kh/wp-content/uploads/2021/10/L1021-014.pdf

## ព័ត៌មានពីសារព័ត៌មាន

១. ជា វណ្ណយុទ្ធ ខ្មែរថាមសស៍ កម្ពុជាចុះហត្ថលេខាលើសេចក្តីព្រាងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយកូរ៉េខាងត្បូង ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០២១ https://www.khmertimeskh.com/50959378/%E1%9E%80%E1%9E%98%E1%9E%96%E1%9E%87%E1%9E%85%E1%9E%A0%E1%9E%8F%E1%9E%90%E1%9E%9B%E1%9E%81/

២. សៀង ភារៈ កាសែតបារាំងអន្តរជាតិ ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០២០ កម្ពុជា-ចិន ចុះកិច្ចព្រមព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងដំណើរទស្សនៈកិច្ចរដ្ឋមន្ត្រីការបរទេសចិន https://www.rfi.fr/km/%E1%9E%80%E1%9E%98%E1%9F%92%E1%9E%96%E1%9E%BB%E1%9E%87%E1%9E%B6/20201011-%E1%9E%80%E1%9E%98%E1%9F%92%E1%9E%96%E1%9E%BB%E1%9E%87%E1%9E%B6-%E1%9E%85%E1%9E%B7%E1%9E%93-

%E1%9E%85%E1%9E%BB%E1%9F%87%E1%9E%80%E1%9E%B7%E1%9E%85%E1%9F%92%E1%9E%85-%E1%9E%96%E1%9F%92%E1%9E%9A%E1%9E%98%E1%9E%96%E1%9F%92%E1%9E%9A%E1%9F%80%E1%9E%84%E1%9E%96%E1%9E%B6%E1%9E%8E%E1%9E%B7%E1%9E%87%E1%9F%92%E1%9E%87%E1%9E%80%E1%9E%98%E1%9F%92%E1%9E%98%E1%9E%9F%E1%9F%81%E1%9E%9A%E1%9E%B8

៣. សឿ ភារៈ ការសែតបារាំងអន្តរជាតិ កិច្ចព្រមព្រៀង RCEP ដែលកម្ពុជាសមាជិកនឹងចូលជាធរមាននាដើមឆ្នាំ ២០២២ https://www.rfi.fr/km/%E1%9E%80%E1%9E%98%E1%9F%92%E1%9E%96%E1%9E%BB%E1%9E%87%E1%9E%B6/20211225-rcep-asean-free-trade-agreement

៤. ធូ វិរៈ ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០២០ ទំហំឥណទានស្នើមក ARDB កើនដល់ $៣១លានលំhttps://www.postkhmer.com/%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B%E1%9E%80%E1%9E%B7%E1%9E%85%E1%9F%92%E1%9E%85/%E1%9E%91%E1%9F%86%E1%9E%A0%E1%9F%86%E1%9E%A5%E1%9E%8E%E1%9E%91%E1%9E%B6%E1%9E%93%E1%9E%9F%E1%9F%92%E1%9E%93%E1%9E%BE%E1%9E%98%E1%9E%80-ardb-%E1%9E%80%E1%9E%BE%E1%9E%93%E1%9E%8A%E1%9E%9B%E1%9F%8B-%E1%-9F%A3%E1%9F%A1-%E1%9E%9B%E1%9E%B6%E1%9E%93

Social Action for Community and Development Organisation (SAC/D)

FOCUS ON THE GLOBAL SOUTH

**រៀបចំ និងផលិតដោយ៖**

People's Action for Development Organization (PAD)

សម្ព័ន្ធបងប្អូនស្រី

United Sisterhood Alliance

អាសយដ្ឋាន៖ ផ្ទះលេខ១៦៨AZ ផ្លូវលេខ២៧BT សង្កាត់បឹងទំពន់ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ